# អនុសញ្ញាស្តីពីសិទ្ធិកុមារ

## សេចក្តីពន្យល់ទូទៅលេខ២១ (ឆ្នាំ២០១៧) ស្តីពីកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់



អនុម័តដោយគណៈកម្មាធិការស្តីពីសិទ្ធិកុមារ

UNITED NATIONS

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia

unicef
for every child

*00000000144*

ចែកជូនដោយឥតគិតថ្លៃ

អនុសញ្ញាស្តីពី
សិទ្ធិកុមារ

ការចែកចាយ៖ ទូទៅ
ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៧

ច្បាប់ដើម៖ ភាសាអង់គ្លេស

គណៈកម្មាធិការសិទ្ធិកុមារ

# សេចក្តីពន្យល់ទូទៅលេខ២១ (ឆ្នាំ២០១៧) ស្តីពី កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់

GE.១៧-១០១៨៧ (E)

Please recycle

# មាតិកា

*ទំព័រ*

កថាមុខ ៣

I. សេចក្តីផ្តើម: "ផ្លាស់ប្តូររឿងរ៉ាវជីវិតរបស់យើង" ៦

II. បរិបទរួម ៦

III. គោលបំណង ១០

IV. យុទ្ធសាស្រ្តរួមរយៈពេលវែងផ្អែកលើអភិក្រមតាមសិទ្ធិកុមារ ១១

V. មាត្រាសំខាន់ៗនៃអនុសញ្ញាពាក់ព័ន្ធនឹងស្ថានភាពកុមារតាមចិញ្ចើមថ្នល់ ២០

VI. ការផ្សព្វផ្សាយ និងកិច្ចសហប្រតិបត្តិការ ៤៦

# អារម្ភកថា

សិទ្ធិមនុស្សត្រូវបានយកមកអនុវត្តចំពោះបុគ្គលគ្រប់រូប ហើយកុមារក៏ត្រូវមានសិទ្ធិដូចគ្នាទៅនឹងសិទ្ធិរបស់មនុស្សពេញវ័យផងដែរ។ ទោះជាយ៉ាងនេះក៏ដោយ ក៏អនុសញ្ញាស្តីពីសិទ្ធិកុមារផ្តោតជាសំខាន់តែទៅលើកុមារ ដើម្បីធានាថា កុមារទាំងអស់ត្រូវបានទទួលស្គាល់ថាជាម្ចាស់នៃសិទ្ធិ ដែលជារឿយៗ តែងត្រូវការកិច្ចការពារ និងការថែរក្សាពិសេស នៅក្នុងដំណើរការទទួល និងប្រើប្រាស់សិទ្ធិរបស់ខ្លួន។ អនុសញ្ញានេះរួមបញ្ចូលនូវប្រភេទទាំងអស់នៃសិទ្ធិមនុស្ស មានដូចជាសិទ្ធិពលរដ្ឋ សិទ្ធិវប្បធម៌ សិទ្ធិសេដ្ឋកិច្ច សិទ្ធិនយោបាយ និងសិទ្ធិសង្គម។ លើសពីនេះទៅទៀត អនុសញ្ញាស្តីពីសិទ្ធិកុមារ គឺជាសន្ធិសញ្ញាសិទ្ធិមនុស្សមួយ ដែលទទួលបានការផ្តល់សច្ចាប័នច្រើនជាងគេបំផុត ហើយមានអានុភាពចងកាតព្វកិច្ចតាមផ្លូវច្បាប់ចំពោះរដ្ឋភាគីទាំងអស់។

រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារកាលពីឆ្នាំ១៩៩២ ដែលតាមរយៈនេះ ប្រទេសកម្ពុជាត្រូវជាប់កាតព្វកិច្ចផ្លូវច្បាប់ដែលកំណត់ក្នុងបទប្បញ្ញត្តិនៃអនុសញ្ញា។ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា កំណត់ឱ្យរដ្ឋទទួលស្គាល់ និងគោរពសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដោយបានរៀបរាប់បញ្ជាក់យ៉ាងច្បាស់អំពីអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិកុមារ។ ម្យ៉ាងវិញទៀត មាត្រា៤៨ នៃរដ្ឋធម្មនុញ្ញខាងលើក៏បានតម្រូវឱ្យរដ្ឋការពារសិទ្ធិទាំងឡាយរបស់កុមារដែលមានចែងក្នុង "អនុសញ្ញាស្តីពីកុមារ"។

គណៈកម្មាធិការស្តីពីសិទ្ធិកុមារ គឺជាស្ថាប័នមួយដែលមានអ្នកជំនាញឯករាជ្យចំនួន១៨រូប ហើយដែលត្រូវបានបង្កើតឡើងដើម្បីពិនិត្យតាមដានការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ដោយរដ្ឋភាគីទាំងអស់។ គណៈកម្មាធិការនេះ ក៏បានផ្សព្វផ្សាយការបកស្រាយខ្លឹមសារនៃបទប្បញ្ញត្តិទាំងឡាយស្តីពីសិទ្ធិមនុស្ស ហើយដែលត្រូវបានកំណត់ឈ្មោះថាជាសេចក្តីពន្យល់ទូទៅ ដែលអាចផ្តោតទៅលើប្រធានបទជាក់លាក់ណាមួយ។ ដោយសារប្រទេសកម្ពុជា គឺជារដ្ឋភាគីមួយនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ហើយដែលបានប្តេជ្ញាទទួលស្គាល់ និងគោរពបទប្បញ្ញត្តិនៃអនុសញ្ញា ដូច្នេះ រាជរដ្ឋាភិបាលគប្បីប្រើប្រាស់ការបកស្រាយ និងការពន្យល់បន្ថែមដែលធ្វើឡើងដោយគណៈកម្មាធិការនេះ។

នៅក្នុងខែមិថុនា ឆ្នាំ២០១៧ គណៈកម្មាធិការស្ដីពីសិទ្ធិកុមារ បានអនុម័តសេចក្ដីពន្យល់ទូទៅលេខ២១ ស្ដីពីកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ ទោះជាកុមារដែលកំពុងស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់មិនត្រូវបានចែងយ៉ាងជាក់លាក់នៅក្នុងអនុសញ្ញាស្ដីពីសិទ្ធិកុមារក៏ដោយ ក៏ប្រភេទកុមារទាំងនេះត្រូវទទួលបានសិទ្ធិទាំងឡាយដែលមានចែងក្នុងអនុសញ្ញា ដូចគ្នាទៅនឹងកុមារផ្សេងៗទៀតផងដែរ។ ពិសេសជាងនេះទៅទៀត កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ គឺជាប្រភេទអ្នកងាយរងគ្រោះបំផុត ព្រោះថា សិទ្ធិភាគច្រើនលើសលុបដែលមានចែងក្នុងអនុសញ្ញាត្រូវបានគេរំលោភបំពានជាញឹកញាប់។ សេចក្ដីពន្យល់ទូទៅលេខ២១ បានផ្ដល់ជាគោលការណ៍ណែនាំដល់រដ្ឋទាំងឡាយ ក្នុងការអនុវត្តតាមអភិក្រមតាមសិទ្ធិកុមារ និងគ្រប់ជ្រុងជ្រោយសម្រាប់កសាង និងអនុវត្តន៍យុទ្ធសាស្ត្រ និងគំនិតផ្ដួចផ្ដើមទាំងឡាយ ទាក់ទងនឹងកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ ជាងនេះទៅទៀត សេចក្ដីពន្យល់ទូទៅលេខ២១ បានគូសបញ្ជាក់អំពីមាត្រាជាក់លាក់នៃអនុសញ្ញា ដែលអាចត្រូវយកមកអនុវត្តសំដៅលើកកម្ពស់ការគោរពកុមារទាំងនោះក្នុងឋានៈពួកគេជាម្ចាស់នៃសិទ្ធិ និងជាប្រជាពលរដ្ឋពេញលក្ខណៈ ព្រមទាំងសំដៅលើកកម្ពស់ការយល់ដឹងអំពីកត្តាផ្សេងៗដែលផ្សារភ្ជាប់កុមារទាំងនោះទៅនឹងចិញ្ចើមថ្នល់។

សេចក្ដីពន្យល់ទូទៅលេខ២១មានលក្ខណៈពាក់ព័ន្ធខ្លាំងទៅនឹងបរិបទជាក់ស្ដែងនៅកម្ពុជា។ នៅក្នុងរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ដែលត្រូវបានផ្សព្វផ្សាយកាលពីខែកញ្ញា ឆ្នាំ២០១៧ អ្នករាយការណ៍ពិសេសបានកំណត់ថា "កុមារ" និង "បុគ្គលដែលស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់" គឺជាប្រភេទនៃក្រុមមនុស្សងាយរងគ្រោះបំផុត។ នៅក្នុងរបាយការណ៍នោះ លោកស្រីបានស្នើឱ្យរាជរដ្ឋាភិបាលកម្ពុជា ចាត់វិធានការឱ្យបានឆាប់រហ័ស សំដៅអនុវត្តអនុសាសន៍នានាដែលលើកឡើងនៅក្នុងសន្និសីទថ្នាក់ជាតិស្ដីពីបុគ្គលដែលស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ហើយដែលត្រូវបានរៀបចំឡើងនៅរាជធានីភ្នំពេញ កាលពីខែធ្នូ ឆ្នាំ២០១៥។ ទន្ទឹមនឹងការលើកឡើងអំពីការអនុម័តច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ដែលជាច្បាប់ថ្មីមួយ មានវិសាលភាពគ្របដណ្ដប់លើស្ថានភាពគ្មានលំនៅឋាន(បុគ្គលដែលស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់) ថាជាជំហានដ៏វិជ្ជមានមួយក្នុងការអនុវត្តសិទ្ធិកុមារ អ្នករាយការណ៍ពិសេសក៏បានគូសបញ្ជាក់អំពីសារសំខាន់ ដែលរាជរដ្ឋាភិបាល ត្រូវការកៀងគរធនធានមនុស្ស និងហិរញ្ញវត្ថុចាំបាច់ សំដៅធានាការអនុវត្តច្បាប់នេះឱ្យបានពេញលេញ និងធ្វើការពិនិត្យតាមដានការអនុវត្តយ៉ាងហ្មត់ចត់ ហើយសំដៅធានាឱ្យមានការគោរពបទប្បញ្ញត្តិទាំងឡាយ ដែលមានចែងក្នុងអនុសញ្ញាស្ដីពីសិទ្ធិកុមារ។

អាស្រ័យដូចបានរៀបរាប់ខាងលើ  ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR កម្ពុជា) សម្រេចបោះពុម្ពផ្សាយឯកសារគន្លឹះនេះជាភាសាខ្មែរ ក្នុងសេចក្តីសង្ឃឹមថា អត្ថបទនេះនឹងជួយរាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត ក្នុងការខិតខំធានាថា កុមារទាំងអស់ រួមទាំងកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ទទួលបាន និងប្រើប្រាស់សិទ្ធិរបស់ពួកគេ ដូចមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ។

**ការិយាល័យឧត្តមស្នងការ**
**អង្គការសហប្រជាជាតិ**
**ទទួលបន្ទុកសិទ្ធិមនុស្ស**
**ការិយាល័យប្រចាំនៅកម្ពុជា**
**ខែវិច្ឆិកា ឆ្នាំ២០១៧**

## I. សេចក្តីផ្តើម៖ "ផ្លាស់ប្តូររឿងរ៉ាវជីវិតរបស់យើង"

១. សេចក្តីពន្យល់ទូទៅនេះ ស្តែងចេញតាមរយៈកិច្ចពិគ្រោះយោបល់ជាមួយកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ បានសង្កត់ធ្ងន់អំពីតម្រូវការឱ្យមានការគោរព សេចក្តីថ្លៃថ្នូរ និងសិទ្ធិ។ នៅក្នុងការសម្តែងអារម្មណ៍របស់ពួកគេ ពួកគេបាននិយាយជាអាទិ៍ "សូមផ្តល់ការគោរពចំពោះយើងក្នុងនាមជាមនុស្សផង" "ខ្ញុំចង់ឱ្យអ្នកដែលមិនធ្លាប់រស់នៅតាមចិញ្ចើមផ្លូវមើលមកយើងថាជាមនុស្សដែលមានមោទនភាពដូចមនុស្សធម្មតាដែរ" "បញ្ហាមិនមែននៅត្រង់យកយើងចេញពីចិញ្ចើមផ្លូវ ហើយផ្តល់ជម្រកឱ្យយើងនោះទេ។ គឺត្រូវផ្តល់ឱ្យយើងនូវឋានៈមួយ" "រដ្ឋាភិបាលមិនគួរនិយាយថាពួកយើងមិនត្រូវរស់នៅតាមចិញ្ចើមផ្លូវនោះទេ។ អាជ្ញាធរមិនត្រូវរំខាន/យាយីយើង ដោយសារតែពួកយើងនៅតាមចិញ្ចើមផ្លូវនោះដែរ។ ពួកយើងគួរតែត្រូវបានទទួលយក" "ការរស់នៅតាមចិញ្ចើមផ្លូវ មិនមានន័យថាយើងមិនអាចមានសិទ្ធិនោះទេ" "នៅតាមចិញ្ចើមផ្លូវមានផលប៉ះពាល់ជាច្រើន៖ បញ្ហានៅត្រង់ថាតើយើងត្រូវដើរចេញ ឬបន្តរស់នៅតទៅទៀត" "យើងមិនចង់បានជំនួយ សប្បុរសធម៌ ការអាណិតអាសូរនោះទេ។ រដ្ឋាភិបាលត្រូវធ្វើការជាមួយសហគមន៍ដើម្បីផ្តល់សិទ្ធិឱ្យយើង។ យើងមិនសុំក្តីសប្បុរសទេ។ ខ្ញុំចង់ក្លាយជាមនុស្សម្នាក់ដែលអាចថែទាំខ្លួនឯងបាន" "អ្នកគួរផ្តល់ឱកាសឱ្យយើងប្រើអំណោយទាន និងទេពកោសល្យពីធម្មជាតិ ដើម្បីសម្រេចក្តីសុបិន្តរបស់យើង" "សូមផ្តល់ឱកាសឱ្យយើង ដើម្បីផ្លាស់ប្តូររឿងរ៉ាវជីវិតរបស់យើង" [1]។

## II. បរិបទទូទៅ

### គោលបំណង

២. នៅក្នុងសេចក្តីពន្យល់ទូទៅនេះ គណៈកម្មាធិការសិទ្ធិកុមារផ្តល់ការណែនាំជាផ្លូវការដល់រដ្ឋនានា អំពីការបង្កើតយុទ្ធសាស្ត្រជាតិដ៏ទូលំទូលាយ និងមានរយៈពេលវែង សម្រាប់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ដោយប្រើប្រាស់អភិក្រមតាមសិទ្ធិកុមាររួម និងដោះ

[1] រាល់សម្រង់ទាំងអស់ គឺដកស្រង់ចេញពីការពិគ្រោះយោបល់ ឬសំណើរយោបល់ជាលាយលក្ខណ៍អក្សរដល់ឯកសារសេចក្តីពន្យល់ទូទៅនេះ។ សារទាំងនេះបានមកពីក្មេងៗជាបន្តបន្ទាប់ដូចតទៅ៖ កុមារមកពីបង់ក្លាដែស(យោបល់ជាលាយលក្ខណ៍អក្សរពីទីក្រុងដាកា) កុមារមកពីអាមេរិកឡាទីន(កិច្ចពិគ្រោះយោបល់នៅម៉ិកស៊ិក)។ កុមារាអាយុ១៥ឆ្នាំមកពីប្រទេសប្រេស៊ីល ក្មេងប្រុស និងក្មេងស្រីអាយុ១៨ឆ្នាំមកពីឥណ្ឌា កុមារនិងយុវវ័យមកពីសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ កុមារនិងយុវវ័យមកពីអឺរ៉ុប (កិច្ចពិគ្រោះយោបល់នៅទីក្រុងព្រុចសែល) កុមារាអាយុ ១៦ឆ្នាំមកពីប៉ាគីស្ថាន កុមារាមកពីប្រទេសហ្ស៊ីមបាវ៉េ និងក្មេងប្រុសអាយុ១៨ឆ្នាំម្នាក់មកពីប្រេស៊ីល។

ស្រាយទាំងការបង្ការ និងការឆ្លើយតបស្របតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ទោះបីជាអនុសញ្ញានេះ មិនបាននិយាយយោងឲ្យបានច្បាស់ដល់កុមារទាំងនោះក៏ដោយ ក៏បទប្បញ្ញត្តិទាំងអស់របស់អនុសញ្ញា អាចយកមកអនុវត្តចំពោះកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមផ្លូវ ដែលជួបប្រទះនូវការរំលោភបំពានមួយផ្នែកធំនៃមាត្រាជាច្រើនរបស់អនុសញ្ញានេះ។

## ការពិគ្រោះយោបល់

៣. កិច្ចប្រជុំពិគ្រោះយោបល់ត្រូវបានរៀបចំឡើងនៅ៧តំបន់ផ្សេងៗគ្នា មានការចូលរួមជាសរុបពីកុមារនិងមនុស្សធំទង់ចំនួន ៣២៧នាក់ មកពី៣២ប្រទេស។ តំណាងសង្គមស៊ីវិលបានឆ្លើយតបទៅនឹងការអំពាវនាវជាទូទៅដល់ការផ្តល់យោបល់ ហើយសេចក្តីព្រាងចុងក្រោយត្រូវបានចែករំលែកជាមួយរដ្ឋភាគី។

## វាក្យស័ព្ទ

៤. កាលដើមឡើយ ពាក្យដែលត្រូវបានប្រើ ដើម្បីពណ៌នាកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ រួមមាន "កុមារអនាថា" "កុមារតាមចិញ្ចើមថ្នល់" "កុមារនៅតាមផ្លូវ" "កុមាររត់ចេញពីផ្ទះ" "កុមារត្រូវបានបោះបង់ចោល" "កុមាររស់នៅនិង/ឬធ្វើការនៅតាមចិញ្ចើមថ្នល់" "កុមារគ្មានផ្ទះសម្បែង" និង "កុមារដែលមានទំនាក់ទំនងទៅនឹងចិញ្ចើមថ្នល់"។ នៅក្នុងសេចក្តីពន្យល់ទូទៅនេះ ពាក្យ "កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់" ត្រូវបានប្រើរួមជាអាទិ៍ (ក) កុមារដែលពឹងអាស្រ័យនឹងចិញ្ចើមថ្នល់ដើម្បីរស់និង/ឬធ្វើការ ទោះតែម្នាក់ឯង ជាមួយមិត្តភក្តិ ឬគ្រួសារ និង(ខ) ជាក្រុមដ៏ទូលាយមួយរបស់កុមារដែលបានបង្កើតដោយចំណងយ៉ាងរឹងមាំទៅនឹងទីសាធារណៈ និងសំរាប់អ្នកទាំងឡាយណាដែលយកចិញ្ចើមផ្លូវធ្វើជាទីកន្លែងដ៏សំខាន់ នៅក្នុងជីវិតប្រចាំថ្ងៃ និងធ្វើជាអត្តសញ្ញាណរបស់ពួកគេ។ ក្រុមដ៏ទូលាយមួយនេះរួមបញ្ចូលទាំងកុមារដែលម្តងម្កាល ប៉ុន្តែមិនតែងតែរស់នៅនិង/ឬធ្វើការជាប់ជាប្រចាំនៅតាមចិញ្ចើមថ្នល់នោះទេ និងកុមារដែលមិនរស់នៅ ឬធ្វើការតាមចិញ្ចើមថ្នល់ទេ ប៉ុន្តែរួមដំណើរជាទៀងទាត់ជាមួយមិត្តភក្តិ បងប្អូន ឬគ្រួសារនៅតាមចិញ្ចើមថ្នល់។ ពាក់ព័ន្ធនឹងកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ "ការស្ថិតនៅទីសាធារណៈ" ត្រូវយល់ដោយរួមទាំងការចំណាយពេលច្រើននៅតាមចិញ្ចើមថ្នល់ ឬផ្សារតាមចិញ្ចើមផ្លូវ សួនច្បារសាធារណៈ ទីផ្លា ឬទីលានសហគមន៍សាធារណៈ និងរថយន្តក្រុង និងស្ថានីយរថភ្លើង។ ពាក្យនេះមិនរាប់បញ្ចូល អគារសាធារណៈ ដូចជា សាលារៀន មន្ទីរពេទ្យ ឬស្ថាប័នផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែលទេ។

## ការសង្កេតចំបងៗ

៥. មានអភិក្រមផ្សេងៗគ្នាជាច្រើន ត្រូវបានប្រើប្រាស់ចំពោះកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ផ្ទួនកាលជាអភិក្រមបញ្ចូលគ្នា។ អភិក្រមទាំងនេះរួមមានអភិក្រមតាមសិទ្ធិកុមារ ដែលកុមារទទួលបានការគោរពថាជាអ្នកកាន់កាប់សិទ្ធិ ហើយការសម្រេចនានា ជារឿយៗត្រូវធ្វើឡើងជាមួយកុមារ។ អភិក្រមសុខុមាលភាពពាក់ព័ន្ធនឹង "ការជួយសង្គ្រោះ" កុមារដែលត្រូវបានមើលឃើញថាជាកម្មវត្ថុ ឬជាជនរងគ្រោះពីចិញ្ចើមថ្នល់ ហើយការសម្រេចនានា ត្រូវបានធ្វើឡើងសម្រាប់កុមារ ដោយមិនចាំបាច់ពិចារណាពេកលើទស្សនៈរបស់កុមារឡើយ និងអភិក្រមបែបគាបសង្កត់ មិនបានយកចិត្តទុកដាក់កុមារថាជាអ្នកកាន់កាប់សិទ្ធិនោះទេ ហើយជាលទ្ធផលបណ្តាលឱ្យមានការប្រមូលកុមារពីចិញ្ចើមផ្លូវដោយបង្ខំ ដែលកាន់តែបំពានលើសិទ្ធិរបស់ពួកគេថែមទៀត។ ការអះអាងដែលថា អភិក្រមសុខុមាលភាព និងអភិក្រមបែបគាបសង្កត់បំរើឱ្យឧត្តមប្រយោជន៍របស់កុមារនោះ តាមពិតទៅមិនបានធ្វើឱ្យអភិក្រមទាំងពីរនេះផ្តែកលើសិទ្ធិទេ។[2] ដើម្បីអនុវត្តអនុសញ្ញានេះ ជាការប្រសើរត្រូវអនុវត្តវិធីសាស្ត្រ/អភិក្រមតាមសិទ្ធិកុមារ។

៦. កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់មិនមែនសុទ្ធតែជាក្រុមដូចគ្នានោះទេ។ លក្ខណៈសម្បត្តិ ត្រូវបែងចែកទៅតាមអាយុ ភេទ ជាតិពន្ធុ អត្តសញ្ញាណជាតិដើម សញ្ជាតិ ពិការភាព ទំនោរផ្លូវភេទ និងអត្តសញ្ញាណ/ការបង្ហាញយេនឌ័រ ក្នុងចំណោមលក្ខខណ្ឌដទៃទៀត។ ភាពចំរុះនេះ បង្ហាញពីបទពិសោធន៍ ហានិភ័យ និងតម្រូវការផ្សេងៗគ្នា។ ប្រភេទ និងពេលវេលាដែលកុមារបានចំណាយជាក់ស្តែងនៅតាមចិញ្ចើមថ្នល់ មានភាពខុសគ្នាគួរឱ្យកត់សំគាល់ពីក្មេងម្នាក់ទៅម្នាក់ អាស្រ័យទៅតាមប្រភេទ និងវិសាលភាពនៃទំនាក់ទំនងជាមួយមិត្តភក្តិ សមាជិកគ្រួសារ សមាជិកសហគមន៍ តួអង្គសង្គមស៊ីវិល និងអាជ្ញាធរសាធារណៈ។ ទំនាក់ទំនងរបស់កុមារ អាចជួយឱ្យពួកគេមានជីវិតរស់នៅតាមចិញ្ចើមថ្នល់ និង/ឬបន្តរក្សាស្ថានភាពនៃការរំលោភបំពានហិង្សាលើសិទ្ធិរបស់ពួកគេ។ កុមារធ្វើសកម្មភាពជាច្រើនតាមទីសាធារណៈ រួមមាន ការបំពេញការងារ សកម្មភាពសង្គម ការកំសាន្ត/ការសំរាកលំហែ ជម្រកកន្លែងដេកពួន កន្លែងដាំស្លហូបចុក បោកគក់ និងពាក់ព័ន្ធក្នុងការប្រើប្រាស់គ្រឿងញៀន ឬសកម្មភាពផ្លូវភេទ។ កុមារអាចពាក់ព័ន្ធនឹងសកម្មភាពបែបនេះដោយស្ម័គ្រចិត្ត ដោយសារខ្វះជម្រើសដែលអាចសម្រេចបាន ឬតាមរយៈការបង្ខិតបង្ខំ ឬការវាយធ្វើបាបពីកុមារដទៃ ឬ

2 សូមមើលសេចក្តីពន្យល់ទូទៅលេខ១៣ (២០១១) ស្តីពីសិទ្ធិកុមារមានសេរីភាពចាកផុតពីអំពើហិង្សាតាមគ្រប់ទម្រង់ វាក្យខណ្ឌទី៥៩ និងសេចក្តីពន្យល់ទូទៅលេខ ១៤(២០១៣) ស្តីពីសិទ្ធិកុមារដែលឧត្តមប្រយោជន៍របស់កុមារត្រូវបានយកមកពិចារណាជាបឋម។

មនុស្សពេញវ័យ។ កុមារអាចធ្វើសកម្មភាពទាំងនេះតែម្នាក់ឯង ឬដោយមានការជួយពីសមាជិកក្រុមគ្រួសារ[3] មិត្តភក្តិ អ្នកស្គាល់គ្នា សមាជិកក្រុមអន្ធពាល ឬមិត្តភក្តិដែលកេងប្រវ័ញ្ចពីកុមារធំ/ចាស់ជាង និង/ឬមនុស្សពេញវ័យ។

៧. ជារឿយៗ ទិន្នន័យមិនត្រូវបានប្រមូល ឬបែងចែកតាមប្រភេទជាលក្ខណៈប្រព័ន្ធទេ ដូច្នេះគេមិនដឹងថាមានកុមារប៉ុន្មាននាក់កំពុងស្ថិតនៅតាមចិញ្ចើមថ្នល់។ តួលេខប៉ាន់ស្មានប្រែប្រួលទៅតាមនិយមន័យដែលយកមកប្រើ ដែលឆ្លុះបញ្ចាំងពីលក្ខខណ្ឌសង្គមសេដ្ឋកិច្ចនយោបាយ វប្បធម៌ និងលក្ខខណ្ឌដទៃទៀត។ កង្វះខាតទិន្នន័យ ធ្វើឱ្យកុមារទាំងនេះ ត្រូវបានបំភ្លេចចោលដោយមិនមានការតាក់តែងគោលនយោបាយឬគ្រាន់តែជាវិធានការចំពោះកិច្ច បណ្ដោះអាសន្ន ឬមានរយៈពេលខ្លី។ ការណ៍នេះបណ្ដាលឱ្យមានការរំលោភបំពានសិទ្ធិជាច្រើនដែលបង្ខំឲ្យក្មេងទៅនៅតាមចិញ្ចើមថ្នល់ ហើយការរំលោភបំពាននេះនៅតែបន្តកើតឡើងនៅពេលដែលកុមារស្ថិតនៅតាមចិញ្ចើមថ្នល់។ បញ្ហានេះជាក្ដីកង្វល់ដល់គ្រប់ប្រទេស។

៨. មូលហេតុ ប្រេវ៉ាឡង់ និងបទពិសោធន៍របស់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ខុសៗគ្នាទាំងនៅក្នុងរដ្ឋ និងពីរដ្ឋមួយទៅរដ្ឋមួយទៀត។ វិសមភាពដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច ពូជសាសន៍ និងយេនឌ័រ គឺជាមូលហេតុក្នុងចំណោមមូលហេតុជារចនាសម្ព័ន្ធនៃការកើតមាន និងការផាត់ចេញកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ បញ្ហាទាំងនេះកាន់តែធ្ងន់ធ្ងរដោយភាពខ្សត់ខ្សោយខាងសម្ភារៈ កិច្ចគាំពារសង្គមមិនគ្រប់គ្រាន់ ការវិនិយោគមិនចំគោលដៅ អំពើពុករលួយ និងគោលនយោបាយសារពើពន្ធ (ការប្រមូលពន្ធ និងការចំណាយ) ដែលកាត់បន្ថយ ឬលុបបំបាត់លទ្ធភាពរបស់ប្រជាជនក្រីក្រមិនឱ្យងើបផុតពីភាពក្រីក្រ។ អស្ថិរភាពភ្លាមៗ ដែលបណ្ដាលមកពីជម្លោះ គ្រោះទុរ្ភិក្ស ការរីករាលដាលនៃជំងឺឆ្លង គ្រោះមហន្តរាយធម្មជាតិ ឬការបណ្ដេញចេញដោយបង្ខំ ឬព្រឹត្តិការណ៍ដែលនាំទៅដល់ការភៀសខ្លួន ឬការធ្វើចំណាកស្រុកដោយបង្ខំ បង្កើនបន្ទុកបន្ថែមទៀតដល់អានុភាពនៃមូលហេតុជារចនាសម្ព័ន្ធនេះ។ មូលហេតុផ្សេងទៀតរួមមាន៖ អំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច និងការធ្វេសប្រហែសរបស់គ្រួសារនៅផ្ទះ ឬនៅមណ្ឌលថែទាំ ឬគ្រឹះស្ថានអប់រំ (រួមទាំងផ្នែកសាសនាផងដែរ) មរណភាពរបស់អ្នកថែទាំ ការបោះបង់ចោលកុមារ (រួមទាំងដោយសារមេរោគអេដស៍/ជំងឺអេដស៍)[4] ភាពអត់ការងារធ្វើរបស់អ្នកថែទាំ គ្រួសារដែលស្ថិត

---

[3] សម្រាប់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ជាមួយគ្រួសាររបស់ពួកគេ សេចក្ដីពន្យល់ទូទៅនេះ ផ្ដោតលើកុមារ ថាជាអ្នកកាន់កាប់សិទ្ធិចំបង។ ក្នុងករណីដែលកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ មានកូននៅតាមខ្លួនពួកគេផ្ទាល់នោះ ឧត្តមប្រយោជន៍របស់កុមារនៃជំនាន់នីមួយៗរបស់កុមារត្រូវតែយកចិត្តទុកដាក់ជាបឋម។

[4] សូមមើលសេចក្ដីពន្យល់ទូទៅលេខ៣ (២០០៣) ស្ដីពីមេរោគអេដស៍/ជំងឺអេដស៍ និងសិទ្ធិកុមារ វាក្យខណ្ឌទី៧

ក្នុងស្ថានភាពអាក្រក់ ការបែកបាក់គ្រួសារ គ្រួសារពហុពន្ធភាព[5] ការដាច់ចេញពីការអប់រំ ការប្រើប្រាស់គ្រឿងញៀន និងបញ្ហាសុខភាពផ្លូវចិត្ត(របស់កុមារ ឬគ្រួសារ) ការមិនអនុគ្រោះ និងការរើសអើង រួមទាំងការរើសអើងកុមារពិការ កុមារដែលត្រូវបានចោទប្រកាន់ពីអំពើអាបធ្មប់ អតីតទាហានកុមារដែលត្រូវបានក្រុមគ្រួសារបដិសេធចោល និងកុមារដែលត្រូវដាច់ចេញពីគ្រួសារដោយសារបញ្ហាផ្លូវភេទ ឬការកំណត់អត្តសញ្ញាណភេទរបស់ពួកគេ ថាជាអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រលាញ់ភេទទាំងពីរ អ្នកប្តូរភេទ អ្នកដែលមានភេទមិនច្បាស់ និងអ្នកដែលគ្មានអារម្មណ៍ភេទ ព្រមទាំងគ្រួសារដែលមិនមានលទ្ធភាពទទួលយកចំលើយបដិសេធរបស់កុមារចំពោះការអនុវត្តប្រកបដោយគ្រោះថ្នាក់ ដូចជាអាពាហ៍ពិពាហ៍វ័យកុមារ និងការកាត់ទ្រិបប្រដាប់ភេទស្ត្រីជាដើម។[6]

## III. គោលបំណង

៩. គោលបំណងនៃសេចក្តីពន្យល់ទូទៅនេះរួមមាន៖

(ក). បំភ្លឺពីកាតព្វកិច្ចរបស់រដ្ឋក្នុងការអនុវត្តអភិក្រមតាមសិទ្ធិកុមារ ចំពោះយុទ្ធសាស្ត្រ និងការផ្តួចផ្តើមគំនិតសម្រាប់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។

(ខ). ផ្តល់ការណែនាំគ្រប់ជ្រុងជ្រោយ និងប្រកបដោយសិទ្ធិអំណាចដល់រដ្ឋនានាក្នុងការប្រើប្រាស់អភិក្រមតាមសិទ្ធិកុមារនិងគ្រប់ជ្រុងជ្រោយ៖ ដើម្បីបង្ការកុមារដែលទទួលរងការរំលោភសិទ្ធិនិងកង្វះជម្រើសដែលនាំឱ្យពួកគេត្រូវពឹងអាស្រ័យលើចិញ្ចើមថ្នល់ដើម្បីរស់ និងអភិវឌ្ឍន៍ និងដើម្បីលើកកម្ពស់ និងការពារសិទ្ធិកុមារដែលកំពុងស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ដោយធានាឱ្យមានការថែទាំជាប្រចាំ និងជួយពួកគេឱ្យអភិវឌ្ឍនូវសក្តានុពលពេញលេញបំផុតរបស់ពួកគេ។

(គ). កំណត់ពីភាពជាប់ពាក់ព័ន្ធនៃមាត្រាពិសេសមួយចំនួនរបស់អនុសញ្ញា សម្រាប់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ដើម្បីលើកកំពស់ការគោរពចំពោះពួកគេ ថាជាអ្នកកាន់កាប់សិទ្ធិ និងជាប្រជាពលរដ្ឋពេញលេញ និងលើកកម្ពស់ការយល់ដឹងអំពីការផ្សារភ្ជាប់កុមារតាមចិញ្ចើមថ្នល់។

[5] សូមមើលអនុសាសន៍ទូទៅលេខ៣១របស់គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនារីភេទរួមជាមួយនឹងសេចក្តីពន្យល់ទូទៅលេខ១៨(២០១៤) របស់គណៈកម្មាធិការសិទ្ធិកុមារស្តីពីការអនុវត្តប្រកបដោយគ្រោះថ្នាក់ វាក្យខណ្ឌទី២៥-២៨។

[6] ដូចខាងលើ វាក្យខណ្ឌទី១៩-២៤។

# IV. យុទ្ធសាស្ត្ររួមរយៈពេលវែង ផ្តោតលើអភិក្រមតាមសិទ្ធិកុមារ

## ក. អភិក្រមតាមសិទ្ធិកុមារ

### *ការពណ៌នា*

១០. នៅក្នុងអភិក្រមតាមសិទ្ធិកុមារ ដំណើរការនៃការសម្រេចបានសិទ្ធិកុមារគឺសំខាន់ដូចជាលទ្ធផលចុងក្រោយ។ អភិក្រមតាមសិទ្ធិកុមារធានានូវការគោរពសេចក្តីថ្លៃថ្នូរ ជីវិត ការរស់រានមានជីវិត សុខុមាលភាព ការអភិវឌ្ឍន៍ ការចូលរួម និងការមិនរើសអើង ដោយចាត់កុមារជាអ្នកកាន់កាប់សិទ្ធិ។

១១. យោងតាមមូលនិធិសហប្រជាជាតិដើម្បីកុមារ (UNICEF)[7] អភិក្រមតាមសិទ្ធិកុមារគឺជាអភិក្រមមួយដែល៖

(ក). បន្តការសម្រេចបាននូវសិទ្ធិកុមារដូចមានចែងក្នុងអនុសញ្ញា និងលិខិតតុបករណ៍សិទ្ធិមនុស្សអន្តរជាតិដទៃទៀត។

(ខ). ប្រើប្រាស់ស្តង់ដារ និងគោលការណ៍សិទ្ធិកុមារ ដែលមាននៅក្នុងអនុសញ្ញា និងលិខិតតុបករណ៍សិទ្ធិមនុស្សអន្តរជាតិដទៃទៀត ដើម្បីតម្រែតម្រង់ឥរិយាបទ សកម្មភាព គោលនយោបាយ និងកម្មវិធី ជាពិសេស ការមិនរើសអើង ឧត្តមប្រយោជន៍របស់កុមារ សិទ្ធិមានជីវិត ការរស់រានមានជីវិត និងការអភិវឌ្ឍន៍ សិទ្ធិបញ្ចេញយោបល់ និងទទួលបានការយកចិត្តទុកដាក់លើយោបល់នោះ និងសិទ្ធិទទួលបានការណែនាំពីការអនុវត្តសិទ្ធិរបស់ខ្លួនដោយអ្នកថែទាំ ឪពុកម្តាយ និងសមាជិកសហគមន៍ ស្របតាមសមត្ថភាពវិវឌ្ឍន៍របស់កុមារ។

(គ). កសាងសមត្ថភាពរបស់កុមារជាអ្នកកាន់កាប់សិទ្ធិ ដើម្បីទាមទារសិទ្ធិរបស់ពួកគេ និងសមត្ថភាពរបស់អ្នកជាប់កាតព្វកិច្ច ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនចំពោះកុមារ។

---

[7] សូមមើលយូនីសេហ្វ ឧបករណ៍អប់រំសិទ្ធិកុមារ៖ ការបណ្តុះសិទ្ធិកុមារតាំងពីការអប់រំកុមារតូច ការអប់រំនៅបឋមសិក្សា និងមធ្យមសិក្សា(ហ្សឺណែវ ឆ្នាំ២០១៤) ទំព័រទី២១។ អាចរកបាននៅ
https://www.unicef.org/crc/files/UNICEF_CRE_Toolkit_FINAL_web_version170414.pdf ។
សូមមើលផងដែរសេចក្តីពន្យល់ទូទៅលេខ១៣ វាក្យខណ្ឌទី៥៩។ សូមមើលផងដែរ "អភិក្រមតាមសិទ្ធិមនុស្សចំពោះកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍" ដែលអាចរកបាននៅ http://hrbaportal.org/the-human-rights-based-approach-to-development-cooperation-towards-a-common-understanding-among-un-agencies.

## *ចំណុចសំខាន់ៗនៃកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់*

១២. គណៈកម្មាធិការយល់ឃើញថា យុទ្ធសាស្ត្រ និងគំនិតផ្តួចផ្តើមដែលអនុម័តយកអភិក្រមតាមសិទ្ធិកុមារ បំពេញបានតាមលក្ខណៈវិនិច្ឆ័យសំខាន់ៗសម្រាប់ការអនុវត្តល្អប្រសើរ ដោយមិនគិតពីកម្រិត ឬបរិបទឡើយ។ កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ជាញឹកញាប់ មិនទុកចិត្តចំពោះការជួយអន្តរាគមន៍ពីមនុស្សពេញវ័យ នៅក្នុងជីវិតរបស់ពួកគេទេ។ ការប្រព្រឹត្តដោយបំពានលើកុមារដោយមនុស្សពេញវ័យនៅក្នុងសង្គម បានធ្វើឱ្យពួកគេមិនមានបំណងបោះបង់ចោលនូវការខិតខំប្រឹងប្រែងអស់ពីសមត្ថភាពរបស់ខ្លួន ដើម្បីទទួលបានជោគជ័យ ទោះបីជាមានកម្រិតក៏ដោយ។ អភិក្រមនេះសង្កត់ធ្ងន់ទៅលើការគោរពយ៉ាងពេញលេញដល់ស្វ័យភាពរបស់ពួកគេ រួមទាំងការគាំទ្រពួកគេដើម្បីស្វែងរកជម្រើសផ្សេងក្រៅពីអាស្រ័យលើការរស់នៅតាមចិញ្ចើមថ្នល់។ វាលើកកម្ពស់ភាពធន់ទ្រាំនិងសមត្ថភាពរបស់ពួកគេ បង្កើនលទ្ធភាពក្នុង ការធ្វើសេចក្តីសម្រេចជាស្ថាប័ន និងផ្តល់អំណាចដល់ពួកគេ ជាតួអង្គសេដ្ឋកិច្ចសង្គម នយោបាយ និងវប្បធម៌។ អភិក្រមនេះ កសាងលើមូលដ្ឋាននៃភាពខ្លាំងដែលមានស្រាប់របស់ពួកគេ និងវិភាគទានជាវិជ្ជមានដែលពួកគេមាន ដើម្បីការរស់រានមានជីវិត និងការអភិវឌ្ឍន៍សម្រាប់ខ្លួនគេផ្ទាល់ និងក៏សំរាប់មិត្តភក្តិ ក្រុមគ្រួសារ និងសហគមន៍របស់ពួកគេដែរ។ ការអនុវត្តតាមអភិក្រមនេះ មិនត្រឹមតែជាសីលធម៌ និងអាណត្តិបញ្ញាតាមផ្លូវច្បាប់នោះទេ ប៉ុន្តែក៏ជាអភិក្រមដែលមាននិរន្តរភាពបំផុត សម្រាប់កំណត់ និងអនុវត្តដំណោះស្រាយរយៈពេលវែងជាមួយកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។

## ខ. យុទ្ធសាស្ត្រជាតិ

### *ទិដ្ឋភាពទូទៅ*

១៣. ដើម្បីអនុលោមតាមកាតព្វកិច្ចដែលមានចែងនៅក្នុងអនុសញ្ញា រដ្ឋទាំងឡាយត្រូវបានជម្រុញឱ្យអនុម័តយកយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយនិងយូរអង្វែង ព្រមទាំងមានកញ្ចប់ថវិកាចាំបាច់សម្រាប់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ បញ្ហា និងដំណើរនីតិវិធីប្រទាក់ក្រឡាគ្នា ត្រូវលើកយកមកបង្ហាញខាងក្រោមនេះ បន្ទាប់ពីខ្លឹមសារតាមប្រធានបទដែលត្រូវដោះស្រាយនៅក្នុងយុទ្ធសាស្ត្រនេះ។ ជាអ្នកជំនាញអំពីឆាកជីវិតផ្ទាល់របស់ខ្លួន កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ត្រូវចូលរួមកសាង និងអនុវត្តយុទ្ធសាស្ត្រនេះ។ ជំហានដំបូង រដ្ឋត្រូវប្រមូលព័ត៌មានអំពីកុមារក្នុងស្ថានភាពបែបនេះនៅក្នុងប្រទេសរបស់ខ្លួនដើម្បីសម្រេចអំពីការលើកកំពស់សិទ្ធិរបស់ពួកគេ ឱ្យបានល្អបំផុតតាមវិធីណា។ រដ្ឋត្រូវយកវិធីសាស្ត្រឆ្លង

វិស័យ ដើម្បីស្វែងយល់ថាតើគោលនយោបាយនៅក្នុងវិស័យមួយ ឧទាហរណ៍ដូចជា ហិរញ្ញវត្ថុ ប៉ះពាល់យ៉ាងដូចម្តេចដល់គោលនយោបាយមួយផ្សេងទៀត ដូចជាវិស័យអប់រំ ដែលជះឥទ្ធិពលដល់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់យ៉ាងដូចម្តេច។ រដ្ឋគប្បីលើកទឹកចិត្តដល់កិច្ចសហប្រតិបត្តិការអន្តរវិស័យ និងរវាងរដ្ឋនិងរដ្ឋ។

## *ការពិនិត្យឡើងវិញអំពីច្បាប់ និងគោលនយោបាយ*

១៤. រដ្ឋគប្បីវាយតម្លៃអំពីច្បាប់ និងគោលនយោបាយថាអាចត្រូវបានកែសម្រួលតាមរបៀបណា ដើម្បីឆ្លុះបញ្ចាំងពីអនុសាសន៍នៃសេចក្តីពន្យល់ទូទៅនេះ។ ដោយមានប្រសិទ្ធភាពភ្លាមៗ រដ្ឋគប្បី៖(១)ដកចេញនូវបទប្បញ្ញត្តិទាំងឡាយណាដែលមានការរើសអើងដោយផ្ទាល់ ឬដោយប្រយោល ដោយឈរលើមូលដ្ឋាននៃស្ថានភាពតាមចិញ្ចើមថ្នល់របស់កុមារ ឬឪពុកម្តាយ ឬគ្រួសាររបស់ពួកគេ (២)លុបចោលបទប្បញ្ញត្តិទាំងឡាយដែលអនុញ្ញាតឱ្យ ឬគាំទ្រដល់ការចាប់ប្រមូល ឬការយកចេញតាមទំនើងចិត្តនូវកុមារ និងគ្រួសាររបស់ពួកគេពីចិញ្ចើមថ្នល់ ឬទីសាធារណៈ (៣)លុបចោលតាមការសមស្រប នូវបទល្មើសដែលដាក់ទោស និងធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ដូចជាការសុំទាន ការបំពានបំរាមគោចរ ការដើរអនាថា ការរស់នៅអនាថានិងការរត់ចេញពីផ្ទះជាដើម និង(៤)លុបចោលបទល្មើសដែលផ្តន្ទាទោសកុមារចំពោះភាពជាជនរងគ្រោះនៃការកេងប្រវ័ញ្ចអាជីវកម្មផ្លូវភេទ និងអ្វីដែលគេហៅថាការប្រព្រឹត្តខុសសីលធម៌ដូចជាការរួមភេទក្រៅអាពាហ៍ពិពាហ៍ជាដើម។ រដ្ឋនានាគួរណែនាំ ឬពិនិត្យឡើងវិញនូវច្បាប់ស្តីពីកិច្ចការពារកុមារ ឬកុមារដោយឈរលើមូលដ្ឋាននៃអភិក្រមតាមសិទ្ធិកុមារ និងជាពិសេស ដោះស្រាយកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ ច្បាប់នេះគួរត្រូវបានអនុវត្ត តាមរយៈការដាក់ចេញនូវគោលនយោបាយអាណត្តិ នីតិវិធីប្រតិបត្តិការ គោលការណ៍ណែនាំ ការផ្តល់សេវា យន្តការត្រួតពិនិត្យ និងយន្តការអនុវត្ត ហើយច្បាប់នេះគួរត្រូវបានបង្កើត ដោយសហការជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ រួមទាំងកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ផង។ រដ្ឋអាចត្រូវការបង្កើតគោលនយោបាយពាក់ព័ន្ធថ្នាក់ជាតិ និងនិយមន័យតាមផ្លូវច្បាប់នៃកុមារទាំងនេះ ដោយផ្អែកលើការស្រាវជ្រាវដែលមានការចូលរួម ក្នុងបរិបទដែលមានការចាំបាច់ ដើម្បីជួយសម្រួលដល់ការធ្វើអន្តរាគមន៍ដោយអ្នកមានវិជ្ជាជីវៈ និងសេវាដែលមានអាណត្តិតាមផ្លូវច្បាប់។ ទោះជាយ៉ាងណាក៏ដោយ ដំណើរការនៃការកំណត់និយមន័យតាមផ្លូវច្បាប់ មិនគួរពន្យារពេលចាត់វិធានការដើម្បីដោះស្រាយពីការរំលោភបំពានសិទ្ធិនោះទេ។

## តួនាទីរបស់រដ្ឋ និងការទទួលខុសត្រូវ បទបញ្ជា និងការសម្របសម្រួលនៃតួអង្គមិនមែនរដ្ឋ

១៥. យុទ្ធសាស្ត្រសម្រាប់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ គួរទទួលស្គាល់តួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ។ តួនាទីរបស់រដ្ឋ ទុកជាអ្នកជាប់កាតព្វកិច្ចចម្បងនោះ ត្រូវបានរៀបរាប់នៅផ្នែកទី V ខាងក្រោម។ រដ្ឋមានកាតព្វកិច្ចជួយឪពុកម្តាយ ឬអ្នកថែទាំកុមារ ស្របតាមលទ្ធភាព និងសមត្ថភាពហិរញ្ញវត្ថុដែលខ្លួនមាន និងស្របតាមការវិវឌ្ឍន៍សមត្ថភាពរបស់កុមារ ដើម្បីធានាលក្ខខណ្ឌរស់នៅចាំបាច់ដល់ការអភិវឌ្ឍល្អបំផុតរបស់កុមារ (មាត្រា៥ ១៨ និង ២៧)។ រដ្ឋគួរគាំទ្រផងដែរដល់សង្គមស៊ីវិល ជាជាតួអង្គបំពេញបន្ថែមក្នុងការផ្តល់សេវាកម្មឯកទេស និងផ្ទាល់ដល់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់នូវមូលដ្ឋាននៃអភិក្រមតាមសិទ្ធិកុមារ តាមរយៈការផ្តល់មូលនិធិ ការទទួលស្គាល់ និងបញ្ញត្តិច្បាប់។ វិស័យធុរកិច្ច ត្រូវតែបំពេញការទទួលខុសត្រូវរបស់ខ្លួនចំពោះសិទ្ធិកុមារ ហើយរដ្ឋត្រូវធានាថា ផ្នែកធុរកិច្ចធ្វើដូច្នេះបាន។[8] ត្រូវមានការសម្របសម្រួលរវាងតួអង្គរដ្ឋ និងមិនមែនរដ្ឋ។ រដ្ឋមានកាតព្វកិច្ចតាមផ្លូវច្បាប់ធានាថា អ្នកផ្តល់សេវាមិនមែនរដ្ឋ ត្រូវប្រតិបត្តិ ស្របតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ។[9]

## ការដោះស្រាយភាពស្មុគស្មាញ

១៦. យុទ្ធសាស្ត្រ ត្រូវការដោះស្រាយឬសគល់ចំរុះនៃបញ្ហា រាប់ចាប់ពីវិសមភាពជារចនាសម្ព័ន្ធរហូតដល់អំពើហិង្សាក្នុងគ្រួសារ។ យុទ្ធសាស្ត្រទាំងនេះក៏ត្រូវការយកចិត្តទុកដាក់ចាត់វិធានការអនុវត្តភ្លាមៗ ដូចជាការបញ្ឈប់ការចាប់ប្រមូល ឬការយកចេញតាមទំនើងចិត្តនូវកុមារពីទីសាធារណៈ និងវិធានការដែលត្រូវបានអនុវត្តឱ្យរីកចំរើនជាលំដាប់ ដូចជាកិច្ចការពារសង្គមដ៏គ្រប់ជ្រុងជ្រោយ។ ចាំបាច់ត្រូវមានការរួមបញ្ចូលគ្នាទាំងច្បាប់ គោលនយោបាយ និងការផ្លាស់ប្តូរការផ្តល់សេវាកម្ម។ រដ្ឋគួរប្តេជ្ញាបំពេញឱ្យបានសិទ្ធិមនុស្ស លើសពីកុមារភាពនេះ។ ជាពិសេស រដ្ឋគួរធានាឱ្យមានយន្តការតាមឃ្លាំមើលកុមារនៅក្នុងមណ្ឌលថែទាំជំនួស និងកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ដោយសារតែពួកគេផ្លាស់ប្តូរទៅជាមនុស្សពេញវ័យនៅអាយុ ១៨ឆ្នាំ ដើម្បីចៀសវាងនូវការបញ្ចប់ភ្លាមៗនៃការគាំទ្រ និងសេវាកម្ម។

---

[8] សូមមើលសេចក្តីពន្យល់ទូទៅលេខ១៦ (២០១៣) ស្តីពីកាតព្វកិច្ចរបស់រដ្ឋទាក់ទងនឹងផលប៉ះពាល់នៃវិស័យធុរកិច្ចលើសិទ្ធិកុមារ វាក្យខណ្ឌទី៨។

[9] សូមមើលសេចក្តីពន្យល់ទូទៅលេខ៥ (២០០៣) ស្តីពីវិធានការទូទៅនៃការអនុវត្តអនុសញ្ញានេះ វាក្យខណ្ឌទី៤២-៤៤ សេចក្តីពន្យល់ទូទៅលេខ៧(២០០៥)ស្តីពីការអនុវត្តសិទ្ធិកុមារនៅវ័យកុមារតូច វាក្យខណ្ឌទី៣២ សេចក្តីពន្យល់ទូទៅលេខ៩(២០០៦) ស្តីពីសិទ្ធិកុមារពិការ វាក្យខណ្ឌទី២៥ និងសេចក្តីពន្យល់ទូទៅលេខ១៦ វាក្យខណ្ឌទី២៥។

## *ប្រព័ន្ធការពារកុមារគ្រប់ជ្រុងជ្រោយ*

១៧. ក្នុងក្របខណ្ឌច្បាប់ និងគោលនយោបាយ ការកំណត់ឱកាសសម្រាប់ការតាក់តែង និងការពង្រឹងប្រព័ន្ធការពារកុមាររួមមួយ ដោយផ្អែកលើអភិក្រមតាមសិទ្ធិកុមារ បង្កើតបានជាមូលដ្ឋាននៃវិធានការជាក់ស្តែងដែលតម្រូវដល់យុទ្ធសាស្ត្រទប់ស្កាត់ និងឆ្លើយតប។ ប្រព័ន្ធការពារកុមារថ្នាក់ជាតិបែបនេះ ចាំបាច់ត្រូវទៅដល់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ និងគួរតែបញ្ចូលឱ្យបានពេញលេញនូវសេវាកម្មជាក់លាក់ដែលពួកគេត្រូវការ។ ប្រព័ន្ធនេះត្រូវការផ្តល់ការថែទាំជាបន្តបន្ទាប់ នៅគ្រប់បរិបទដែលពាក់ព័ន្ធ រួមទាំងការបង្ការ ការអន្តរាគមន៍ទាន់ពេល ការផ្សព្វផ្សាយនៅតាមដងផ្លូវ ប្រព័ន្ធទូរស័ព្ទផ្តល់ជំនួយ មណ្ឌលសុំចតស្នាក់នៅបណ្តោះអាសន្ន មជ្ឈមណ្ឌលថែទាំពេលថ្ងៃ ការថែទាំកុមារបណ្តោះអាសន្ននៅតាមសាលា ការជួបជុំក្រុមគ្រួសារ ការថែទាំដោយឪពុកម្តាយធម៌ ការរស់នៅដោយឯករាជ្យ ឬជម្រើសថែទាំរយៈពេលខ្លី ឬវែងផ្សេងទៀត។ ទោះជាយ៉ាងណាក៏ដោយ មិនមែនគ្រប់បរិបទទាំងនេះសុទ្ធតែពាក់ព័ន្ធនឹងកុមារទាំងអស់ស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់នោះទេ។ ឧទា. ការការពារ និងការអន្តរាគមន៍ទាន់ពេល គឺជាអាទិភាពសម្រាប់កុមារនៅតំណាក់កាលដំបូងនៃការបង្កើតចំណងយ៉ាងខ្លាំង និងគ្រោះថ្នាក់ទៅនឹងចិញ្ចើមថ្នល់ ប៉ុន្តែមិនទាក់ទងទៅនឹងកុមារដែលកើតនៅក្នុងស្ថានភាពតាមចិញ្ចើមថ្នល់នោះទេ។ កុមារខ្លះមិនធ្លាប់ឆ្លងកាត់ការដាក់ឱ្យរស់នៅក្នុងមណ្ឌលទេ ខណៈពេលដែលក្មេងផ្សេងទៀត ការជួបជុំក្រុមគ្រួសារ ជារឿងមិនពាក់ព័ន្ធ ឬមិនសមស្របទៅវិញ។ យុទ្ធសាស្ត្រគួរបញ្ជាក់ឱ្យច្បាស់ថា អភិក្រមតាមសិទ្ធិកុមារ ត្រូវអនុវត្តទៅគ្រប់បរិបទ។ បន្ទុករដ្ឋបាល និងការពន្យាពេលក្នុងការទទួលបានប្រព័ន្ធការពារកុមារគួរត្រូវកាត់បន្ថយ។ ព័ត៌មាន គួរតែអាចរកបាន តាមលក្ខណៈកុមារមេត្រី និងទម្រង់ដែលងាយស្រួល ហើយកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ គួរទទួលបានការគាំទ្រឱ្យយល់ដឹង និងស្វែងរកប្រព័ន្ធការពារកុមារ។

## *ការកសាងសមត្ថភាពរបស់អ្នកដែលមានទំនាក់ទំនងជាមួយកុមារ*

១៨. រដ្ឋគួរវិនិយោគ លើការបណ្តុះបណ្តាលបឋម ដែលមានគុណភាពល្អ និងការបណ្តុះបណ្តាលមូលដ្ឋាននៅពេលបំពេញការងារ អំពីសិទ្ធិកុមារ ការការពារកុមារ និងបរិបទក្នុងស្រុករបស់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ដល់អ្នកវិជ្ជាជីវៈទាំងអស់ដែលអាចមកធ្វើការដោយផ្ទាល់ ឬដោយប្រយោលជាមួយកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់នៅក្នុងវិស័យបែបនេះ ដូចជាការធ្វើគោលនយោបាយ ការអនុវត្តច្បាប់ យុត្តិធម៌ ការអប់រំ សុខភាព សង្គម

កិច្ច និងចិត្តវិទ្យា។ ការបណ្តុះបណ្តាលនេះ អាចទាញយកជំនាញពីតួអង្គមិនមែនរដ្ឋ ហើយគួរត្រូវដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់គ្រឹះស្ថានបណ្តុះបណ្តាលពាក់ព័ន្ធ។ ការបណ្តុះបណ្តាលស៊ីជម្រៅបន្ថែមអំពីអភិក្រមតាមសិទ្ធិកុមារ ការគាំទ្រខាងចិត្តសាស្ត្រសង្គម និងការពង្រឹងអំណាចកុមារ តម្រូវឱ្យមានសម្រាប់អ្នកវិជ្ជាជីវៈដែលធ្វើការជាមួយកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ថាជាផ្នែកមួយនៃអាណត្តិរបស់ខ្លួនដែលត្រូវលះបង់ ដូចជា បុគ្គលិកសង្គមកិច្ចដែលធ្វើការជាមួយកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ និងអង្គភាពនគរបាលឯកទេសទទួលបន្ទុកកិច្ចការពារកុមារ។ "ការដើរអប់រំដល់ទីកន្លែង" និង "ការអប់រំតាមផ្លូវ" គឺជាវិធីសាស្ត្របណ្តុះបណ្តាលទៅដល់ទីកន្លែងដ៏សំខាន់មួយ។ ការបណ្តុះបណ្តាលមូលដ្ឋាន និងឯកទេស គួររួមមានការផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយា ក៏ដូចជាការផ្ទេរចំណេះដឹង និងការអភិវឌ្ឍន៍ជំនាញ ហើយគួរលើកទឹកចិត្តដល់ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការអន្តរវិស័យ។ រដ្ឋាភិបាលថ្នាក់ជាតិ និងមូលដ្ឋាន ត្រូវយល់ដឹង និងគាំទ្រដល់តួនាទីដ៏សំខាន់របស់បុគ្គលិកសង្គមកិច្ច រួមទាំង បុគ្គលិកធ្វើការតាមចិញ្ចើមថ្នល់ ក្នុងការកំណត់អត្តសញ្ញាណពីដំបូងទី ដោយផ្តល់ការគាំទ្រដល់គ្រួសារដែលមានកុមារប្រឈមនឹងហានិភ័យ និងកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ អ្នកវិជ្ជាជីវៈ គួរតែចូលរួមក្នុងការចងក្រងនីតិវិធីប្រតិបត្តិ គោលការណ៍ណែនាំអំពីការអនុវត្តល្អប្រសើរ សារាចរណែនាំជាយុទ្ធសាស្ត្រ ផែនការ បទដ្ឋានបំពេញការងារ និងក្រមវិន័យ ហើយគួរទទួលបានការគាំទ្រដើម្បីបំពេញកិច្ចការទាំងនេះជាក់ស្តែង។ រដ្ឋគួរជួយសម្រួលដល់ការយល់ដឹង និងការបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធដទៃទៀតដែលមកធ្វើការដោយផ្ទាល់ ឬដោយប្រយោលជាមួយកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ដូចជា កម្មករដឹកជញ្ជូន តំណាងប្រព័ន្ធផ្សព្វផ្សាយ សហគមន៍ និងមេដឹកនាំសាសនា ព្រមទាំងតួអង្គវិស័យឯកជន ដែលគួរត្រូវបានលើកទឹកចិត្តឱ្យអនុម័តយកគោលការណ៍ធុរកិច្ច និងសិទ្ធិកុមារ។[10]

## *ការផ្តល់សេវា*

១៩. រដ្ឋត្រូវចាត់វិធានការ ដើម្បីធានានូវលទ្ធភាពរបស់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ទទួលបានសេវាជាមូលដ្ឋាន ដូចជាសុខភាព និងការអប់រំ សិទ្ធិទទួលបានយុត្តិធម៌ វប្បធម៌ កីឡា និងព័ត៌មាន។ រដ្ឋត្រូវធានាថា ប្រព័ន្ធការពារកុមាររបស់ខ្លួន ផ្តល់សេវាកម្មឯកទេស

[10] សូមមើល http://childrenandbusiness.org សូមមើលផងដែរនូវសេចក្តីពន្យល់ទូទៅលេខ១៦។

នៅតាមចិញ្ចើមថ្នល់ ដោយមានការចូលរួមពីបុគ្គលិកសង្គមកិច្ចដែលមានការយល់ដឹងខ្ពស់ ទទួលបានការបណ្ដុះបណ្ដាល ពីទំនាក់ទំនងរបស់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ក្នុងមូលដ្ឋាននោះ និងជាអ្នកដែលអាចជួយកុមារឱ្យភ្ជាប់ទំនាក់ទំនងឡើងវិញជាមួយគ្រួសារ សេវាសហគមន៍មូលដ្ឋាន និងសង្គមទាំងមូល។ នេះមិនចាំបាច់ត្រូវតែមានន័យថា កុមារប្រកាសបដិសេធពីជីវិតតាមចិញ្ចើមថ្នល់នោះទេ ប៉ុន្តែយកល្អត្រូវធ្វើអន្តរាគមន៍ ដើម្បីធានាសិទ្ធិរបស់ពួកគេ។ ការបង្ការ ការធ្វើអន្តរាគមន៍ទាន់ពេល និងសេវាគាំទ្រតាមចិញ្ចើមថ្នល់ គឺជាធាតុផ្សំពង្រឹងឱ្យត្មាទៅវិញទៅមក ហើយផ្តល់ការថែទាំជាបន្តបន្ទាប់ ក្នុងយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងរយៈពេលវែងប្រកបដោយប្រសិទ្ធភាព។ ខណៈដែលរដ្ឋគឺជាអ្នកជាប់កាតព្វកិច្ចចម្បង សកម្មភាពសង្គមស៊ីវិលអាចបំពេញបន្ថែមដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋ ក្នុងការអភិវឌ្ឍ និងការផ្តល់សេវាកម្មបែបច្នៃប្រឌិត និងផ្ទាល់ខ្លួន។

## *ការអនុវត្តនៅកម្រិតរដ្ឋាភិបាលថ្នាក់មូលដ្ឋាន*

២០. ការផ្តួចផ្តើមគំនិតដ៏ជោគជ័យ ពឹងផ្អែកលើការយល់ដឹងលម្អិតអំពីបរិបទនៅមូលដ្ឋាន និងការគាំទ្រជាបុគ្គលដល់កុមារ។ ត្រូវមានការយកចិត្តទុកដាក់នៅពេលពង្រីកទំហំគំនិតផ្តួចផ្តើម ដោយមិនត្រូវបំភ្លេចកុមារណាម្នាក់ក្នុងដំណើរការនេះទេ។ រដ្ឋគួរលើកទឹកចិត្ត និងគាំទ្រដល់កិច្ចអន្តរាគមន៍ដែលមានឯកទេស ផ្អែកលើភាពជាដៃគូ និងនៅកម្រិតមូលដ្ឋាន ដោយឈរលើអភិក្រមតាមសិទ្ធិកុមារ តាមទម្រង់តូចៗ និងអាចបត់បែនបាន ដោយមានថវិកាគ្រប់គ្រាន់ ជារឿយៗ ដឹកនាំដោយអង្គការសង្គមស៊ីវិលដែលមានជំនាញនៅមូលដ្ឋាន។ កិច្ចអន្តរាគមន៍ទាំងនេះ ត្រូវសម្របសម្រួលដោយរដ្ឋបាលមូលដ្ឋាន ហើយគាំទ្រដោយរដ្ឋតាមរយៈប្រព័ន្ធការពារកុមារថ្នាក់ជាតិ។ រដ្ឋអាចទាញប្រយោជន៍ពីការគាំទ្រពីវិស័យឯកជន ដល់ធនធានសម្រាប់កសាងសមត្ថភាព និងជំនាញស្ថាប័ន និងពីគ្រឹះស្ថានអប់រំចំពោះសមត្ថភាពស្រាវជ្រាវដើម្បីអាចធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុតាង។ ទីក្រុង និងសហគមន៍កុមារមេត្រី រួមចំណែកដល់បរិយាកាសនៃការទទួលយក និងផ្តល់ជាមូលដ្ឋានដល់បណ្តាញសង្គម ព្រមទាំងប្រព័ន្ធការពារតាមសហគមន៍ សម្រាប់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ គួរទទួលបានការគាំទ្រឱ្យចូលរួមក្នុងដំណើរការរៀបចំផែនការពីថ្នាក់មូលដ្ឋានឡើងទៅតាមបែបវិមជ្ឈការ។

## ការតាមឃ្លាំមើល និងគណនេយ្យភាព

២១. ការអនុវត្តច្បាប់ គោលនយោបាយ និងសេវាប្រកបដោយប្រសិទ្ធភាព ពឹងផ្អែកលើយន្តការតាមឃ្លាំមើល និងគណនេយ្យភាពច្បាស់លាស់ ដែលមានតម្លាភាព និងរឹងមាំ។ រដ្ឋគួរគាំទ្រដល់ការចូលរួមរបស់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ រួមទាំង ក្នុងយន្តការគណនេយ្យភាពសង្គម ដូចជា សម្ព័ន្ធភាពនៃតួអង្គរដ្ឋ និងមិនមែនរដ្ឋ គណៈកម្មាធិការ ឬក្រុមការងារ ដែលតាមឃ្លាំមើលគោលនយោបាយសាធារណៈ ដោយផ្តោតលើ កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ ស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យសម្រាប់លើកកម្ពស់ និងតាមឃ្លាំមើលការអនុវត្តអនុសញ្ញា[11] ដូចជា អំប៊ុតស្មានសិទ្ធិកុមារ ត្រូវតែមានភាពងាយស្រួលក្នុងការទាក់ទងសម្រាប់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។

## សិទ្ធិទទួលបានយុត្តិធម៌ និងដំណោះស្រាយ

២២. កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ដែលធ្លាប់ជាជនរងគ្រោះ ឬជាអ្នករស់រានជីវិតពីការរំលោភបំពានសិទ្ធិមនុស្ស មានសិទ្ធិទទួលបានដំណោះស្រាយតាមផ្លូវច្បាប់ និងតាមវិធីផ្សេងទៀតប្រកបដោយប្រសិទ្ធភាព រួមទាំងតំណាងតាមផ្លូវច្បាប់ផង។ សិទ្ធិនេះ រួមទាំងសិទ្ធិទទួលបានយន្តការបណ្តឹងជាឯកត្តបុគ្គល ដោយកុមារខ្លួនឯងផ្ទាល់ និង/ឬតំណាងដោយមនុស្សពេញវ័យ ក៏ដូចជាយន្តការដោះស្រាយតាមផ្លូវតុលាការ និងក្រៅផ្លូវតុលាការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងស្ថាប័នសិទ្ធិមនុស្សឯករាជ្យ។ នៅពេលដែលប្រើដំណោះស្រាយក្នុងស្រុកអស់ហើយ សិទ្ធិទទួលបានយន្តការសិទ្ធិមនុស្សអន្តរជាតិដែលអាចប្រើប្រាស់បាន គួរតែមាន រួមទាំងនីតិវិធីដែលបានបង្កើតឡើងដោយពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីនីតិវិធីបណ្តឹង។ វិធានការជួសជុលសំណងខូចខាត អាចរួមមានបដិទាន សំណងការខូចខាត ការស្តារនីតិសម្បទា សំណងផ្លូវចិត្ត និងការធានាពីការមិនកើតឡើងវិញនៃការរំលោភសិទ្ធិបែបនេះ។[12]

11 សូមមើលសេចក្តីពន្យល់ទូទៅលេខ២(២០០២) ស្តីពីតួនាទីរបស់ស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យក្នុងការលើកស្ទួយនិងការការពារសិទ្ធិកុមារ វាក្យខណ្ឌទី២ និង១៥

12 សូមមើល www.ohchr.org/EN/ProfessionalInterest/Pages/RemedyAndReparation.aspx ។

## ការប្រមូលទិន្នន័យ និងការស្រាវជ្រាវ

២៣. ក្នុងភាពជាដៃគូជាមួយស្ថាប័នអប់រំ សង្គមស៊ីវិល និងវិស័យឯកជន រដ្ឋគួរបង្កើតយន្តការដែលមានការចូលរួម បែបជាប្រព័ន្ធ និងមានការគោរពសិទ្ធិមនុស្ស ដើម្បីប្រមូលទិន្នន័យ និងចែករំលែកព័ត៌មានដាច់ពីគ្នាអំពីកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ រដ្ឋត្រូវធានាថា ការប្រមូល និងការប្រើប្រាស់ព័ត៌មានបែបនេះ មិនបង្កស្លាកស្នាមទុរយស ឬប៉ះពាល់ដល់កុមារទាំងនេះឡើយ។ ការប្រមូលទិន្នន័យអំពីកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់គួរតែត្រូវបានបញ្ចូលទៅក្នុងការប្រមូលទិន្នន័យកុមារថ្នាក់ជាតិដោយធានាថា ទិន្នន័យជាតិមិនពឹងផ្អែកតែទៅលើការអង្កេតតាមគ្រួសារប៉ុណ្ណោះ ប៉ុន្តែថែមទាំងគ្របដណ្តប់លើកុមារដែលរស់នៅខាងក្រៅផ្ទះផងដែរ។ កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ គួរចូលរួមក្នុងការកំណត់គោលបំណង និងរបៀបវារៈនៃការស្រាវជ្រាវ និងក្នុងការប្រមូលព័ត៌មាន វិភាគ និងផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវ ដល់អ្នកតាក់តែងគោលនយោបាយ និងរៀបចំអន្តរាគមន៍តាមឯកទេស។[13] ស្ថានភាពតាមចិញ្ចើមថ្នល់ មានការផ្លាស់ប្តូរឆាប់រហ័ស ហើយការស្រាវជ្រាវត្រូវធ្វើឡើងជាប្រចាំ ដើម្បីធានាឱ្យគោលនយោបាយ និងកម្មវិធីដើរទាន់សម័យកាល។

[13] សូមមើល ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស-អភិក្រមតាមសិទ្ធិមនុស្សក្នុងការប្រមូលទិន្នន័យ- អាចរកបាននៅwww.ohchr.org/Documents/Issues/HRIndicators/GuidanceNoteonApproachtoData.pdf.

## V. មាត្រាសំខាន់ៗនៃអនុសញ្ញា ពាក់ព័ន្ធនឹងកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់

### ទិដ្ឋភាពទូទៅ

២៤. សិទ្ធិទាំងអស់ដែលមានចែងនៅក្នុងអនុសញ្ញា និងពិធីសារបន្ថែម មានទំនាក់ទំនងរវាងគ្នា និងមិនអាចបំបែកពីគ្នាបានសំរាប់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ក៏ដូចជាសំរាប់កុមារទាំងអស់។ សេចក្តីពន្យល់ទូទៅនេះ គួរអានរួមគ្នាជាមួយនឹងសេចក្តីពន្យល់ទូទៅដទៃទៀតរបស់គណៈកម្មាធិការ។ សេចក្តីពន្យល់ទូទៅនេះ ផ្តោតលើមាត្រាទាំងឡាយដែលមានសារៈសំខាន់ជាពិសេសសម្រាប់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ និងដែលមិនធ្លាប់មានពីមុនមកនៅក្នុងសេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការ។ ឧទាហរណ៍ ទោះបីជាបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងអំពើហិង្សា ការអប់រំ យុត្តិធម៌អនីតិជន និងសុខភាព មានសារៈសំខាន់យ៉ាងច្បាស់ក៏ដោយ ក៏បទប្បញ្ញត្តិទាំងនេះត្រូវបានលើកឡើងនៅទីនេះ ថាជាសេចក្តីយោងដល់សេចក្តីពន្យល់ទូទៅដែលមានស្រាប់។ ម្យ៉ាងវិញទៀត មាត្រាដទៃខ្លះទៀតទទួលបានការពិនិត្យពិច័យយ៉ាងធំធេង ដោយផ្តល់ភាពពាក់ព័ន្ធនៃមាត្រាទាំងនេះដល់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ហើយការពិតដែលថាមាត្រាទាំងនេះមិនធ្លាប់ត្រូវបានស្វែងយល់កាលពីមុនឱ្យបានពិស្តារដោយគណៈកម្មាធិការ។ មាត្រាដែលបានសម្រាំងដូចខាងក្រោមនេះ មិនបញ្ជាក់ពីភាពលើសលុបនៃសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ លើសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់នោះទេ។

### ក. មាត្រាដែលមានការពាក់ព័ន្ធជាទូទៅក្នុងអភិក្រមតាមសិទ្ធិកុមារ

*មាត្រា២ ស្តីពីការមិនរើសអើង*

*ការមិនរើសអើងដោយឈរលើមូលដ្ឋាននៃដើមកំណើតសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃទៀត*

២៥. រដ្ឋត្រូវគោរព និងធានាឱ្យសិទ្ធិកុមារដូចមានចែងក្នុងអនុសញ្ញាសំរាប់កុមារម្នាក់ៗ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយគ្មានការរើសអើងតាមប្រភេទណាមួយឡើយ។ ទោះជាយ៉ាងណា ក៏ការរើសអើងគឺជាបុព្វហេតុចំបងមួយក្នុងចំណោមបុព្វហេតុចំបងដទៃទៀត នៃកុមារដែលនៅទីបំផុតត្រូវស្ថិតនៅតាមចិញ្ចើមថ្នល់។ បន្ទាប់មក កុមារត្រូវបានគេរើសអើងដោយសារតែពួកគេនៅតាមចិញ្ចើមថ្នល់នោះគឺឈរលើមូលដ្ឋាននៃដើមកំណើតសង្គមទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃទៀតដែលនាំឱ្យមានផលវិបាកជាអវិជ្ជមានអស់មួយជីវិត។

គណៈកម្មាធិការបកស្រាយ "ស្ថានភាពដទៃទៀត" តាមមាត្រា២ នៃអនុសញ្ញានេះ ដោយដាក់បញ្ចូលនូវស្ថានភាពតាមចិញ្ចើមថ្នល់របស់កុមារ ឬឪពុកម្តាយ និងសមាជិកគ្រួសារដទៃទៀតរបស់ពួកគេ។

## *ការរើសអើងជាប្រព័ន្ធ*[14]

២៦. ការរើសអើងអាចកើតមានឡើងដោយផ្ទាល់ឬដោយប្រយោល។[15] ការរើសអើងដោយផ្ទាល់រួមមានគោលនយោបាយមិនសមាមាត្រ ឆ្ពោះទៅ "ដោះស្រាយភាពគ្មានផ្ទះសម្បែង" ដែលអនុវត្តនូវកិច្ចខិតខំដាក់ការគៀបសង្កត់ ដើម្បីទប់ស្កាត់ការសុំទាន ការដើរអនាថា ការរស់នៅអនាថា ការរត់ចេញពីផ្ទះ ឬអាកប្បកិរិយាឱ្យតែរស់ ឧទាហរណ៍ដូចជាការដាក់ឱ្យទៅជាព្រហ្មទណ្ឌនៃបទល្មើសឋានៈ[16] ការបោសសម្អាតកុមារពីចិញ្ចើមថ្នល់ ឬ "ការចាប់ប្រមូល" និងអំពើហិង្សា ការបៀតបៀន និងការគំរាមកំហែងដែលកំណត់មុខសញ្ញាដោយកម្លាំងនគរបាល។ ការរើសអើងដោយផ្ទាល់ អាចរួមមាន៖ ការបដិសេធដោយនគរបាល ពីការយកកំណត់ហេតុត្រឹមត្រូវ ពីកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ពីបទលួច ឬហិង្សា ការប្រព្រឹត្តដោយមានការរើសអើងក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន ការបដិសេធពីបុគ្គលិកសង្គមកិច្ច គ្រូបង្រៀន ឬអ្នកមានវិជ្ជាជីវៈថែទាំសុខភាព ក្នុងការធ្វើការជាមួយកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ និងការបៀតបៀន ការបង្អាប់ និងការគំរាមកំហែងពីមិត្តភក្តិ និងគ្រូបង្រៀននៅតាមសាលារៀន។ ការរើសអើងដោយប្រយោលរួមមាន គោលនយោបាយដែលបណ្តាលឱ្យមានការផាត់ចេញពីសេវាមូលដ្ឋាន ដូចជាសុខភាពនិងការអប់រំ ឧទាហរណ៍តាមរយៈការតម្រូវឱ្យបង់ប្រាក់ ឬការផ្តល់ឯកសារអត្តសញ្ញាណផ្សេងៗជាដើម។ ទោះបីជាកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ មិនត្រូវបានកាត់ផ្តាច់ពីសេវាមូលដ្ឋានក៏ដោយ ក៏ពួកគេនៅតែស្ថិតនៅដាច់ឆ្ងាយពីប្រព័ន្ធបែបនេះដែរ។ កុមារអាចប្រឈមមុខនឹងការរើសអើងច្រើនទម្រង់និងអន្តរវិស័យ ឧទាហរណ៍ដូចជាឈរលើមូលដ្ឋាននៃយេនឌ័រ ទំនោរផ្លូវភេទ អត្តសញ្ញាណ/ចំណាប់អារម្មណ៍យេនឌ័រ ពិការភាព ពូជសាសន៍ ជាតិពន្ធុ ឋានៈជាជនជាតិដើមភាគតិច[17]

---

[14] សូមមើលសេចក្តីពន្យល់ទូទៅលេខ២០ (២០០៩) របស់គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ស្តីពីការមិនរើសអើងនៅក្នុងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ វាក្យខណ្ឌទី១២។

[15] ដូចខាងលើ វាក្យខណ្ឌទី១០។

[16] សូមមើលសេចក្តីពន្យល់ទូទៅលេខ៤ (២០០៣) ស្តីពីសុខភាពរបស់យុវវ័យ និងការអភិវឌ្ឍ នៅក្នុងបរិបទនៃអនុសញ្ញា វាក្យខណ្ឌទី១២ និងសេចក្តីពន្យល់ទូទៅលេខ១០ (២០០៧) ស្តីពីសិទ្ធិកុមារក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន វាក្យខណ្ឌទី៨-៩។

[17] សូមមើលសេចក្តីពន្យល់ទូទៅលេខ១១ (២០០៩) ស្តីពីកុមារជនជាតិភាគតិច និងសិទ្ធិរបស់ពួកគេ តាមអនុសញ្ញានេះ។

ឋានៈអន្តោប្រវេសន៍ និងឋានៈជាជនភាគតិចដទៃទៀត ជាពិសេស ជាក្រុមជនភាគតិច ជារឿយៗ ត្រូវបានតំណាងដោយលើសលុបក្នុងចំណោមកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ កុមារដែលទទួលរងការរើសអើង ងាយរងគ្រោះជាង ដោយអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច ការឆ្លងជម្ងឺកាមរោគ រួមទាំងមេរោគអេដស៍ ហើយសុខភាព និងការអភិវឌ្ឍរបស់ពួកគេ ត្រូវប្រឈមនឹងហានិភ័យយ៉ាងខ្លាំង។[18] រដ្ឋត្រូវចងចាំថា ការធានាការពារសិទ្ធិមិនឱ្យមានការរើសអើងមិនគ្រាន់តែជាកាតព្វកិច្ចអកម្ម ដើម្បីហាមឃាត់រាល់ទម្រង់នៃការរើសអើងនោះទេ ប៉ុន្តែទាមទារឱ្យមានវិធានការសមស្រប កាន់តែសកម្មជាងមុន ដើម្បីធានាឱ្យមានឱកាសស្មើគ្នាប្រកបដោយប្រសិទ្ធភាពសំរាប់កុមារទាំងអស់ ក្នុងការទទួលបានសិទ្ធិដូចមានចែងក្នុងអនុសញ្ញានេះ។ ការណ៍នេះតម្រូវឱ្យមានវិធានការជាវិជ្ជមាន សំដៅកែតម្រូវស្ថានភាពនៃវិសមភាពជាសារវន្ត។[19] ការរើសអើងជាប្រព័ន្ធ គឺជាការឆ្លើយតបចំពោះការផ្លាស់ប្តូរច្បាប់ និងគោលនយោបាយ ហើយហេតុដូច្នេះ យើងអាចដោះស្រាយការរើសអើងជាប្រព័ន្ធបាន តាមរយៈការផ្លាស់ប្តូរច្បាប់ និងគោលនយោបាយ។ កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ បានលើកឡើងពីការរើសអើង និងអាកប្បកិរិយាអវិជ្ជមានរបស់សាធារណជនទូទៅដែលពួកគេប្រឈមថាជាការបារម្ភជាក់លាក់ ហើយស្នើសុំឱ្យមានការលើកកម្ពស់ការយល់ដឹង និងវិធានការអប់រំដើម្បីទប់ស្កាត់បញ្ហាទាំងនេះ។

### *លុបបំបាត់ការរើសអើង*

**២៧.** ការរើសអើងគួរតែត្រូវបានលុបបំបាត់ជាផ្លូវការ ដោយធានាថា រដ្ឋធម្មនុញ្ញ ច្បាប់ និងគោលនយោបាយរបស់រដ្ឋមិនរើសអើង ដោយឈរលើមូលដ្ឋាននៃស្ថានភាពនៅតាមចិញ្ចើមថ្នល់នោះទេ និងកាន់តែស៊ីជំរៅនោះ តាមរយៈការយកចិត្តទុកដាក់ឱ្យបានគ្រប់គ្រាន់ដល់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ថាជាក្រុមដែលទទួលរងនូវការរើសអើងជាដរាប និងដែលតម្រូវឱ្យមានសកម្មភាពឆ្លើយតបជាវិជ្ជមាន។[20] វិធានការពិសេសបណ្ដោះអាសន្នដែលចាំបាច់ដើម្បីពន្លឿន ឬសម្រេចបាននូវសមភាពជាក់ស្តែងរបស់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ មិនគួរត្រូវចាត់ទុកជាការរើសអើងឡើយ។ រដ្ឋគួរធានាថា ⁽¹⁾កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ត្រូវស្មើភាពគ្នាចំពោះមុខច្បាប់ ⁽²⁾រាល់ការរើសអើងដោយឈរលើ

[18] សូមមើលសេចក្តីពន្យល់ទូទៅលេខ៤ វាក្យខណ្ឌទី៦ និងសេចក្តីពន្យល់ទូទៅលេខ៣ វាក្យខណ្ឌទី៧។

[19] សូមមើលសេចក្តីពន្យល់ទូទៅលេខ១៤ វាក្យខណ្ឌទី៤១។

[20] សូមមើលសេចក្តីពន្យល់ទូទៅលេខ២០ របស់គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ វាក្យខណ្ឌទី៨។

មូលដ្ឋាននៃស្ថានភាពនៅតាមចិញ្ចើមថ្នល់នោះត្រូវបានហាមឃាត់ (៣)ការញុះញង់ឱ្យរើសអើង និងការយាយីត្រូវតែដោះស្រាយ[21] (៤)កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ និងគ្រួសាររបស់ពួកគេ មិនត្រូវបានដកហូតដោយបំពាននូវទ្រព្យសម្បត្តិរបស់ពួកគេឡើយ និង (៥)បង្រ្កាមគោចរត្រូវធ្វើឡើងដោយស្របច្បាប់ សមាមាត្រនិងមិនរើសអើង។ រដ្ឋក៏គួរបញ្ជ្រាបដល់អ្នកវិជ្ជាជីវៈ វិស័យឯកជន និងសាធារណ នូវបទពិសោធន៍ និងសិទ្ធិរបស់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ក្នុងគោលបំណងផ្លាស់ប្តូរអាកប្បកិរិយាជាវិជ្ជមាន។ រដ្ឋគួរតែគាំទ្រដល់កម្មវិធីច្នៃប្រឌិត សិល្បៈ វប្បធម៌ និង/ឬកម្មវិធីកីឡា ដែលដឹកនាំ ឬចូលរួមដោយកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ដែលជួយដោះស្រាយពីទស្សនៈខុសឆ្គង និងទំលាយរបាំងនានាជាមួយអ្នកវិជ្ជាជីវៈ សហគមន៍ រួមទាំងកុមារដទៃទៀត និងជាមួយសង្គមទាំងមូលតាមរយៈកិច្ចសន្ទនា និងអន្តរកម្មទៅវិញទៅមកដែលអាចមើលឃើញច្បាស់។ ការណ៍នេះអាចរួមបញ្ចូល ការសម្តែងសៀកតាមដងផ្លូវ ល្ខោន តន្ត្រី សិល្បៈនិងការប្រកួតកីឡា។ រដ្ឋគួរតែធ្វើការបោះពុម្ព ចាក់ផ្សាយ និងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីផ្សព្វផ្សាយ និងបង្កើនការយល់ដឹង និងសារដែលមិនបង្កស្លាកស្នាមទុរយស និងសាច់រឿង ដោយឈរលើមូលដ្ឋាននៃអភិក្រមតាមសិទ្ធិកុមារ។ ការភ័យខ្លាចរបស់សាធារណជនពីបទល្មើសដែលប្រព្រឹត្តដោយកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ជារឿយៗត្រូវបានបញ្ឆេះដោយប្រព័ន្ធផ្សព្វផ្សាយ ហើយដែលប្រាសចាកពីការពិត។ ប្រព័ន្ធផ្សព្វផ្សាយគួរត្រូវបានជម្រុញយ៉ាងសកម្មឱ្យប្រើប្រាស់ទិន្នន័យនិងភស្តុតាងត្រឹមត្រូវ ព្រមទាំងអនុលោមទៅតាមស្តង់ដារកិច្ចការពារកុមារ ដើម្បីការពារសេចក្តីថ្លៃថ្នូររបស់កុមារ សន្តិសុខរាងកាយ និងសុចរិតភាពផ្លូវចិត្ត។

### *មាត្រា៣(១) អំពីឧត្តមប្រយោជន៍របស់កុមារ*

២៨. កាតព្វកិច្ចភ្ជាប់នឹងសិទ្ធិនេះ គឺជាមូលដ្ឋានគ្រឹះ ថាជាផ្នែកមួយនៃអភិក្រមតាមសិទ្ធិកុមារ ដើម្បីធានាបាននូវបូរណភាពរូបកាយ ផ្លូវចិត្ត និងសីលធម៌ពេញលេញរបស់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ និងលើកកម្ពស់សេចក្តីថ្លៃថ្នូរជាមនុស្សរបស់ពួកគេ។ កុមារទាំងនេះត្រូវបានកំណត់ថាជាជនងាយរងគ្រោះជាពិសេស។ ដូចដែលគណៈកម្មាធិការបានលើកឡើងហើយថា ឧត្តមប្រយោជន៍របស់កុមារ ក្នុងស្ថានភាពជាក់លាក់នៃភាពងាយរងគ្រោះនឹងមិនសុទ្ធតែដូចគ្នាទៅនឹងស្ថានភាពរបស់កុមារទាំងអស់ ដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះដូចគ្នានោះទេ។ អាជ្ញាធរ និងអ្នកធ្វើសេចក្តីសម្រេច ត្រូវគិតគូរអំពីកម្រិត និងប្រភេទ

---

[21] ដូចខាងលើ វាក្យខណ្ឌទី៧។

ខុសគ្នានៃភាពងាយរងគ្រោះរបស់កុមារម្នាក់ៗ ដោយសារតែកុមារម្នាក់ៗ មានលក្ខណៈពិសេស រៀងៗខ្លួន ហើយស្ថានភាពនីមួយៗ ត្រូវតែបានវាយតម្លៃដោយយោងទៅតាមលក្ខណៈពិសេសរបស់កុមារនោះ។[22] នៅក្នុងបរិបទនេះ "ភាពងាយរងគ្រោះ" គួរត្រូវបានពិចារណារួមគ្នាជាមួយភាពធន់ទ្រាំ និងលទ្ធភាពពឹងផ្អែកលើខ្លួនឯងបានជាបុគ្គលរបស់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។

## *មាត្រា៦ ស្តីពីសិទ្ធិមានជីវិត ការរស់រានជីវិត និងការអភិវឌ្ឍន៍*

### *សិទ្ធិមានជីវិត*

២៩. កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ប្រឈមនឹងហានិភ័យជាអាទិ៍ ⁽¹⁾ការសម្លាប់ក្រៅប្រព័ន្ធតុលាការដោយភ្នាក់ងាររដ្ឋ ⁽²⁾ឃាតកម្មដោយមនុស្សពេញវ័យ ឬមិត្តភក្តិ រួមទាំងឃាតកម្មពាក់ព័ន្ធនឹងអ្វីដែលហៅថាយុត្តិធម៌តាមដងផ្លូវ និងការចងសម្ព័ន្ធជាមួយ ឬការកំណត់មុខសញ្ញាដោយឧក្រិដ្ឋជន និងក្រុមអន្ធពាល ហើយនៅពេលដែលរដ្ឋមិនបានទប់ស្កាត់ឧក្រិដ្ឋកម្មបែបនេះ ⁽³⁾ការបង្ហាញខ្លួនដល់លក្ខខណ្ឌគំរាមកំហែងអាយុជីវិតជាសក្តានុពល ដោយផ្សារភ្ជាប់ជាមួយនឹងទម្រង់គ្រោះថ្នាក់នៃពលកម្មកុមារ គ្រោះថ្នាក់ចរាចរណ៍[23] ការប្រើប្រាស់គ្រឿងញៀន ការកេងប្រវ័ញ្ចពាណិជ្ជកម្មផ្លូវភេទ ការប្រព្រឹត្តផ្លូវភេទមិនមានសុវត្ថិភាពនិងការស្លាប់ដោយសារកង្វះអាហារូបត្ថម្ភគ្រប់គ្រាន់ ការថែទាំសុខភាពនិងជំរក។ សិទ្ធិមានជីវិត មិនគួរត្រូវបានបកស្រាយយ៉ាងចង្អៀតនោះទេ។[24] វាពាក់ព័ន្ធទៅនឹងសិទ្ធិរបស់បុគ្គលម្នាក់ៗក្នុងការទទួលបានសេរីភាព រួចផុតពីអំពើសកម្ម ឬអកម្ម ដែលមានចេតនា ឬរំពឹងទុកថានឹងបង្កឱ្យពួកគេស្លាប់មុនអាយុ ឬមិនទៅតាមធម្មជាតិ ហើយមានសិទ្ធិរស់នៅដោយសេចក្តីថ្លៃថ្នូរ។ នៅក្នុងករណីទារុណកម្ម និងឃាតកម្មដែលប្រព្រឹត្តដោយនគរបាលទៅលើកុមារ៣នាក់ និងយុវជន២នាក់ ដែលរស់នៅក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ក្នុងឆ្នាំ១៩៩០ តុលាការសិទ្ធិមនុស្សអន្តរអាមេរិចបានសម្រេចកាលពីឆ្នាំ១៩៩៩ ថាជាការដកហូតជីវិតតាមទំនើងចិត្ត មិនត្រឹមតែជាអំពើមនុស្សឃាតដោយខុសច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែក៏

[22] សូមមើលសេចក្តីពន្យល់ទូទៅលេខ១៤ វាក្យខណ្ឌទី៧៥-៧៦

[23] សូមមើលសេចក្តីពន្យល់ទូទៅលេខ៤ វាក្យខណ្ឌទី២១

[24] ការងាររៀបចំអនុសញ្ញានេះ បង្ហាញថាសិទ្ធិមានជីវិត ការរស់រានជីវិត និងការអភិវឌ្ឍន៍តាមមាត្រា៦ ត្រូវបានយល់ថា ជាការបំពេញបន្ថែម ហើយមិនត្រូវផ្តាច់ចេញពីគ្នានោះទេ ហើយបង្ហាញថាមាត្រានេះកំណត់ឱ្យមានកាតព្វកិច្ចវិជ្ជមាន(E/CN.4/1988/28)។

ពន្លាតដល់ការដកហូតសិទ្ធិក្នុងការរស់នៅដោយសេចក្តីថ្លៃថ្នូរទៀតផង។ ទស្សនទាននៃសិទ្ធិមានជីវិតនេះ មានវិសាលភាពមិនត្រឹមតែសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនោះទេ ថែមទាំងដល់សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ទៀតផង។ តម្រូវការដើម្បីការពារជនងាយរងគ្រោះបំផុត ដូចជាក្នុងករណីកុមារតាមចិញ្ចើមថ្នល់នេះ ទាមទារជាចាំខាតអោយមានការបកស្រាយពីសិទ្ធិមានជីវិត ដែលត្រូវរួមបញ្ចូលលក្ខខណ្ឌអប្បបរមា សំរាប់ជីវិតរស់នៅដោយសេចក្តីថ្លៃថ្នូរ។[25]

៣០. គណៈកម្មាធិការបានគូសបញ្ជាក់រួចមកហើយថា ការរីកធំធាត់ក្នុងស្ថានភាពក្រីក្រតោកយ៉ាក គំរាមកំហែងដល់ការរស់រានជីវិត និងសុខភាពរបស់ពួកគេ ព្រមទាំងបំផ្លាញគុណភាពជាមូលដ្ឋាននៃជីវិតរបស់ពួកគេទៀតផង។[26]

## *សិទ្ធិរស់រានជីវិត និងការអភិវឌ្ឍន៍*

៣១. គណៈកម្មាធិការរំពឹងថារដ្ឋនឹងបកស្រាយ "ការអភិវឌ្ឍន៍" ជាគំនិតរួមមួយ ដោយប្រកាន់យកនូវការអភិវឌ្ឍន៍របស់កុមារខាងផ្នែករាងកាយ ផ្លូវចិត្ត វិញ្ញាណ សីលធម៌ ស្មារតី និងសង្គម។ កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ មានសកម្មភាពតិចតួច និងអាកប្បកិរិយាដែលត្រូវប្រកាន់យកដើម្បីការរស់រានជីវិតនិងការអភិវឌ្ឍន៍របស់ពួកគេនៅតាមទីសាធារណៈ។ កាតព្វកិច្ចរបស់រដ្ឋតាមមាត្រា៦តម្រូវឱ្យមានការយក ចិត្តទុកដាក់ដោយប្រុងប្រយ័ត្ន ទៅលើអាកប្បកិរិយា និងរបៀបរស់នៅរបស់កុមារទាំងនេះ បើទោះបីជាពួកគេមិនសម្របទៅតាមសហគមន៍ ឬសង្គមជាក់លាក់ណាមួយ កំណត់ថាអាចទទួលយកបានតាមបទដ្ឋានវប្បធម៌ដែលមានស្រាប់សំរាប់ក្រុមអាយុជាយថ្មែរណាមួយក៏ដោយ។ កម្មវិធីអាចមានប្រសិទ្ធភាពបាន លុះត្រាណាពួកគេស្គាល់ពីការពិតនៃកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។[27] ការអន្តរាគមន៍គួរគាំទ្រដល់ កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ជាឯកត្តបុគ្គលឲ្យសម្រេចបាននូវការអភិវឌ្ឍន៍ដ៏ល្អបំផុតរបស់ខ្លួន[28] ដោយបង្កើនការរួមចំណែកជាវិជ្ជមានរបស់ពួកគេជាអតិបរិមាដល់សង្គម។

---

[25] គំនិតរួម, Villagrán Morales et al v. Guatemala តុលាការសិទ្ធិមនុស្សអន្តរអាមេរិច ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៩។ អាចរកបាននៅគេហទំព័រដូចខាងក្រោម www.corteidh.or.cr/docs/casos/articulos/seriec_63_ing.pdf

[26] សូមមើលសេចក្តីពន្យល់ទូទៅលេខ៧ វាក្យខណ្ឌទី២៦

[27] សូមមើលសេចក្តីពន្យល់ទូទៅលេខ៣ កថាខណ្ឌទី១១

[28] សូមមើលសេចក្តីពន្យល់ទូទៅលេខ៥ កថាខណ្ឌទី១២

## ធានាឱ្យជីវិតរស់នៅដោយសេចក្តីថ្លៃថ្នូរ

៣២. រដ្ឋមានកាតព្វកិច្ច (១)គោរពសេចក្តីថ្លៃថ្នូររបស់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ និងសិទ្ធិមានជីវិត ការរស់រានជីវិត និងសិទ្ធិទទួលបានការអភិវឌ្ឍន៍របស់ពួកគេ ដោយត្រូវទប់ស្កាត់អំពើហិង្សាដែលបង្កដោយរដ្ឋ និងមិនត្រូវចាត់ជាបទល្មើសព្រហ្មទណ្ឌទេចំពោះបទល្មើសឋានៈ និងអាកប្បកិរិយាដើម្បីរស់ (២)ការពារកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ឱ្យរួចផុតពីគ្រោះថ្នាក់ដែលបង្កឡើងដោយភាគីទីបី និង (៣)បំពេញនូវសិទ្ធិមានជីវិត ការរស់រានជីវិត និងការអភិវឌ្ឍន៍របស់ពួកគេ តាមរយៈការគាក់តែង និងអនុវត្តយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងរយៈពេលវែង ដោយឈរលើមូលដ្ឋាននៃអភិក្រមតាមសិទ្ធិកុមារ ដើម្បីធានាពីការអភិវឌ្ឍន៍របស់ពួកគេឱ្យដល់កំរិតសក្តានុពលពេញលេញបំផុត។ រដ្ឋគួរជួយគាំទ្រ និងប្រកប ដោយការជឿទុកចិត្តដល់មនុស្សពេញវ័យ ក៏ដូចជាសមាជិកគ្រួសារ ឬបុគ្គលិកសង្គមកិច្ចរដ្ឋឬសង្គមស៊ីវិល ចិត្តវិទូ អ្នកធ្វើការជាមួយឬអ្នកណែនាំក្មេងតាមចិញ្ចើមថ្នល់ ឱ្យចេះជួយកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើម ថ្នល់។ រដ្ឋក៏គួរដាក់ឱ្យអនុវត្តនូវនីតិវិធី និងការអនុវត្តជាក់ស្តែងនៃការរៀបចំពិធីបុណ្យសព ដើម្បីធានាពី សេចក្តីថ្លៃថ្នូរ និងការគោរពចំពោះកុមារដែលស្លាប់នៅតាមផ្លូវ។

## មាត្រា១២ ស្តីពីសិទ្ធិត្រូវបានគេស្តាប់[29]

៣៣. កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ប្រឈមមុខនឹងឧបសគ្គពិសេសក្នុងការធ្វើឱ្យគេដឹងឮ/ស្តាប់ ហើយគណៈកម្មាធិការលើកទឹកចិត្តឱ្យរដ្ឋ ខិតខំប្រឹងប្រែងឱ្យកាន់តែសកម្មដើម្បីជំនះឧបសគ្គទាំងនោះ។ រដ្ឋ និងអង្គការអន្តរដ្ឋាភិបាល ត្រូវផ្តល់ -និងគាំទ្រដល់អង្គការសង្គមស៊ីវិលក្នុងការផ្តល់- ឱ្យកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់នូវបរិយាកាសគាំទ្រ និងអំណោយផលមួយដើម្បី៖ (១)ឱ្យសម្លេងរបស់ពួកគេត្រូវបានគេយកមកពិចារណាក្នុងនីតិវិធីរដ្ឋបាល និងតុលាការ (២)អនុវត្តនូវការផ្តួចផ្តើមគំនិតរបស់ពួកគេ និង(៣)ចូលរួមយ៉ាងពេញលេញទាំងនៅថ្នាក់សហគមន៍ និងថ្នាក់ជាតិ ក្នុងការផ្តល់គំនិត ការគាក់តែង ការអនុវត្ត ការសម្របសម្រួល ការតាមឃ្លាំមើល ការពិនិត្យឡើងវិញ និងការទំនាក់ទំនង លើការរៀបចំកម្មវិធី និង គោលនយោបាយ រួមទាំងតាមរយៈប្រព័ន្ធផ្សព្វផ្សាយ។ ការធ្វើអន្តរាគមន៍ផ្តល់អត្ថប្រយោជន៍បំផុតដល់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ល្គឹកណាកុមារខ្លួនឯងបានចូលរួមយ៉ាងសកម្មក្នុងការវាយតម្លៃពីតម្រូវការ បង្កើតដំណោះស្រាយ រៀបចំយុទ្ធសាស្ត្រ

---

[29] សេចក្តីពន្យល់ទូទៅលេខ១២ (២០០៩) ស្តីពីសិទ្ធិកុមារត្រូវបានគេលឺ/ស្តាប់។

និងអនុវត្តកិច្ចការទាំងនោះ ជាជាងត្រូវបានមើលឃើញថាជាកម្មវត្ថុដែលត្រូវមានការធ្វើសេចក្តីសម្រេចជំនួស។ រដ្ឋក៏គួរស្តាប់មនុស្សពេញវ័យដែលពាក់ព័ន្ធ ដូចជាសមាជិកគ្រួសារ និងសហគមន៍ អ្នកវិជ្ជាជីវៈ និងអ្នកតស៊ូមតិ នៅពេលបង្កើតយុទ្ធសាស្ត្របង្ការ និងយុទ្ធសាស្ត្រឆ្លើយតប។ កិច្ចអន្តរាគមន៍គួរគាំពារដល់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ជាឯកត្តបុគ្គល ឲ្យចេះប្រើសិទ្ធិនិងអភិវឌ្ឍជំនាញ ភាពធន់ទ្រាំ ការទទួលខុសត្រូវ និងភាពជាពលរដ្ឋរបស់ខ្លួន ស្របតាមការវិវឌ្ឍន៍សមត្ថភាពរបស់ពួកគេ។ រដ្ឋគួរគាំទ្រ និងលើកទឹកចិត្តដល់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ឲ្យចេះបង្កើតអង្គការដឹកនាំដោយកុមារដោយខ្លួនឯង និងការផ្តួចផ្តើមគំនិត ដែលនឹងបង្កើតជាលំហសំរាប់ការចូលរួម និងភាពជាតំណាងប្រកបដោយអត្ថន័យ។[30] នៅពេលដែលត្រូវបានការពារយ៉ាងត្រឹមត្រូវ និងទៅតាមការសមស្រប កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ អាចលើកកំពស់ការយល់ដឹង តាមរយៈការចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេដើម្បីកាត់បន្ថយការស្អប់ខ្ពើមនិងការរើសអើង និងដើម្បី ជួយទប់ស្កាត់កុមារដទៃទៀតមិនឱ្យធ្លាក់ទៅក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ដែរ។

## *មាត្រា៤ ស្តីពីវិធានការសមស្រប*

៣៤. យោងតាមមាត្រា៤ រដ្ឋភាគីត្រូវចាត់គ្រប់វិធានការសមស្របផ្នែកច្បាប់ រដ្ឋបាល និងវិធានការដទៃទៀត សំរាប់ការអនុវត្តសិទ្ធិដែលត្រូវបានទទួលស្គាល់នៅក្នុងអនុសញ្ញានេះ។ ការណ៍នេះអនុវត្តចំពោះកុមារគ្រប់រូប ដោយគ្មានការរើសអើង ដោយត្រូវយកចិត្តទុកដាក់ពិសេសចំពោះក្រុមដែលជួបការលំបាកបំផុត ដែលច្បាស់ណាស់រួមទាំងកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។[31] កាតព្វកិច្ចស្នូលអប្បបរមា មានការចាំបាច់សំរាប់រដ្ឋទាំងអស់ យ៉ាងហោចណាស់ ធានាឱ្យបាននូវការពេញចិត្តនៃកម្រិតសំខាន់ជាអប្បបរមានៃសិទ្ធិនីមួយៗនៃសិទ្ធិសង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌[32]។ រដ្ឋត្រូវធានាថា ការណ៍នេះក៏ត្រូវអនុវត្តចំពោះកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ កង្វះខាតធនធានមិនមែនជាសម្អាងហេតុសមស្របឱ្យរដ្ឋមិនអនុវត្តតាមកាតព្វកិច្ចស្នូលនេះទេ។ ដូចដែលគណៈកម្មាធិការបានលើកឡើងហើយថា កាតព្វកិច្ចបន្ទាន់ និងជាអប្បបរមា ដែលកំណត់ដោយសិទ្ធិកុមារ មិនត្រូវបានសម្របសម្រួលជាមួយនឹងវិធានការ ដែលវិលទៅរកសភាពអាក្រក់ដូចដើមនោះទេ បើទោះបីជាក្នុង

[30] សូមមើលដូចខាងលើ កថាខណ្ឌទី១២៨

[31] សូមមើលសេចក្តីពន្យល់ទូទៅលេខ៥ កថាខណ្ឌទី៨

[32] គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សេចក្តីពន្យល់ទូទៅលេខ៣ (១៩៩០) ស្តីពីចរិកលក្ខណៈនៃកាតព្វកិច្ចរបស់រដ្ឋភាគី កថាខណ្ឌទី១០

ពេលមានវិបត្តិសេដ្ឋកិច្ចក៏ដោយ។[33] រដ្ឋត្រូវតែធានាថា កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់មិនត្រូវទទួលរងផលប៉ះពាល់ដោយវិធានការថយក្រោយ នៅពេលមានវិបត្តិសេដ្ឋកិច្ចនោះទេ។

## *មាត្រា៥ ស្តីពីការដឹកនាំ និងការណែនាំស្របតាមការវិវឌ្ឍន៍សមត្ថភាព*

៣៥. ដើម្បីពង្រឹងការទប់ស្កាត់ រដ្ឋគួរតែកសាងសមត្ថភាពមាតាបិតា គ្រួសារសាច់ញាតិ អាណាព្យាបាលស្របច្បាប់ និងសមាជិកសហគមន៍ ឲ្យចេះផ្តល់ការដឹកនាំ និងការណែនាំបានត្រឹមត្រូវដល់កុមារ ដោយជួយពួកគេឱ្យយកចិត្តទុកដាក់ចំពោះទស្សនៈរបស់កុមារស្របតាមអាយុនិងភាពចាស់ទុំរបស់ពួកគេ ផ្តល់បរិយាកាសមួយដែលគាំទ្រ និងមានសុវត្ថិភាព ដែលកុមារអាចអភិវឌ្ឍបាន និងឲ្យចេះទទួលស្គាល់កុមារថាជាអ្នកកាន់កាប់សិទ្ធិសកម្ម ដែលជួយឲ្យកុមារអាចអនុវត្តសិទ្ធិទាំងនោះបាន នៅពេលពួកគេចម្រើនវ័យ តាមរយៈការណែនាំ និងការដឹកនាំត្រឹមត្រូវ។ គណៈកម្មាធិការបានរៀបរាប់ពីគោលការណ៍នៃការវិវឌ្ឍន៍សមត្ថភាពរបស់កុមារថា កុមារដឹងកាន់តែច្រើន មានបទពិសោធន៍ និងយល់កាន់តែច្រើនកាលណា ឪពុកម្តាយឬអាណាព្យាបាលស្របច្បាប់ ត្រូវផ្លាស់ការដឹកនាំនិងការណែនាំ ទៅជាការរំលឹកនិងការផ្តល់ដំបូន្មាន ឲ្យកាន់តែច្រើន ហើយបន្ទាប់មក ឈានដល់ការផ្លាស់ប្តូរគ្នាវិញ ដោយឈរលើមូលដ្ឋានស្មើភាពគ្នា។[34] កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ តម្រូវឱ្យមានការដឹកនាំ និងការណែនាំបែបវិជ្ជមានពិសេស ដែលគោរពដល់បទពិសោធជីវិតរបស់ពួកគេ។ កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ភាគច្រើននៅរក្សាទំនាក់ទំនងជា១ក្រុមគ្រួសារ ហើយមានភស្តុតាងកាន់តែច្រើនឡើងអំពីមធ្យោបាយដ៏មានប្រសិទ្ធភាព ដើម្បីពង្រឹងចំណងគ្រួសារទាំងនោះ។ ប្រសិនបើកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ មិនសូវមាន ឬគ្មានទំនាក់ទំនងល្អជាមួយឪពុកម្តាយ ក្រុមគ្រួសារសាច់ញាតិ ឬអាណាព្យាបាលស្របច្បាប់នោះទេ អញ្ចឹងតួនាទីរបស់សមាជិកសហគមន៍ ដូចបានរៀបរាប់នៅក្នុងមាត្រា៥ នឹងមានអត្ថន័យកាន់តែខ្លាំងក្លា ហើយត្រូវបានយល់ថា នឹងមានរួមបញ្ចូលការគាំទ្រពីមនុស្សពេញវ័យប្រកបដោយការជឿទុកចិត្ត ដែលមានសម្ព័ន្ធភាពជាមួយអង្គការសង្គមស៊ីវិល។

[33] សូមមើលសេចក្តីពន្យល់ទូទៅលេខ១៩ (២០១៦) ស្តីពីការរៀបចំថវិកាសាធារណៈសម្រាប់ការសំរេចបាននូវសិទ្ធិកុមារ កថាខណ្ឌទី៣១។

[34] សូមមើលសេចក្តីពន្យល់ទូទៅលេខ១២ (២០០៩) ស្តីពីសិទ្ធិកុមារត្រូវបានគេឮ/ស្តាប់ កថាខណ្ឌទី៨៤ និងសេចក្តីពន្យល់ទូទៅលេខ១៤ កថាខណ្ឌទី៤៤

## ខ. សិទ្ធិពលរដ្ឋ និងសេរីភាព

### *មាត្រា១៥ស្តីពីសិទ្ធិសេរីភាពខាងសមាគម និងការជួបប្រជុំដោយសន្តិវិធី*

### *ទិដ្ឋភាពទូទៅ*

៣៦. ការរស់នៅជាក់ស្តែងរបស់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់មិនស៊ីគ្នានឹងនិយមន័យតាមបែប ប្រពៃណី ឬទស្សនទានិយកម្មនៃកុមារភាពនោះទេ។ ពួកគេមានទំនាក់ទំនងពិសេសជាមួយនឹងទីកន្លែងសាធារណៈ បើប្រៀបធៀបជាមួយកុមារដទៃ។ ការដាក់កំហិតរបស់រដ្ឋតាមមាត្រា១៥ ទាក់ទងនឹងទីកន្លែងសាធារណៈ អាចមានផលប៉ះពាល់អសមាមាត្រទៅលើកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ រដ្ឋគប្បីធានាថា ការប្រើប្រាស់ទីកន្លែងសាធារណៈ និងទីកន្លែងនយោបាយ ដើម្បីចងក្រងជាសមាគម និងជួបប្រជុំ ដោយសន្តិវិធី មិនគួរត្រូវបានបដិសេធ តាមវិធីរើសអើងនោះទេ។

### *លំហសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ*

៣៧. សមាគមនិងការជួបប្រជុំដោយសន្តិវិធីមានសារៈសំខាន់សម្រាប់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើម ថ្នល់ ដើម្បីទាមទារសិទ្ធិរបស់ពួកគេ ឧទាហរណ៍ តាមរយៈសហជីពការងារកុមារ និងសមាគមដែលដឹកនាំដោយកុមារ។ ទោះជាយ៉ាងណាក៏ដោយ គណៈកម្មាធិការបានសម្តែងនូវការព្រួយបារម្ភជាប្រចាំ នៅក្នុងសេចក្តីសង្កេតសន្និដ្ឋានរបស់ខ្លួន ទាក់ទងនឹងកង្វះលំហនយោបាយបំរុងសម្រាប់កុមារដើម្បីបញ្ចេញមតិ។ ការណ៍នេះ បានរាំងស្ទះជាពិសេសដល់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ដែលជារឿយៗខ្វះទំនាក់ទំនងជាមួយមនុស្សពេញវ័យដែលទុកចិត្តបាន ដែលអាចតម្រូវឱ្យចុះបញ្ជីជាផ្លូវការពីការបង្កើតអង្គការ១។ កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ អាចខ្វះការគាំទ្រក្នុងការបំពេញក្រដាសស្នាម និងទទួលបានព័ត៌មានដើម្បីបង្កើតសមាគម និងគំនិតផ្តួចផ្តើមក្នុងការប្រមូលផ្តុំដោយសន្តិ វិធី។ កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ អាចត្រូវបានជួលឲ្យចូលរួមក្នុងការតវ៉ា ឬការជួបប្រជុំណាមួយ។ ពួកគេអាចងាយរងគ្រោះពីការរកេងប្រវ័ញ្ច និងមិនដឹងអំពីផលប៉ះពាល់នៃការចូលរួមក្នុងព្រឹត្តិការណ៍បែបនេះ ដែលបង្កើតជាចំណោទដ៏ស្មុគស្មាញអំពីតម្រូវការដើម្បីថ្លឹងថ្លែងរវាងកិច្ចការពារ និងសិទ្ធិចូលរួម។ ទោះជាយ៉ាងណាក៏ដោយ ដូច ដែលគណៈកម្មាធិការបានលើកឡើងនៅក្នុងសេចក្តីសង្កេតសន្និដ្ឋានរបស់ខ្លួន ចាចំណោទនេះ មិនគួរត្រូវប្រើជាលេសដើម្បីកាត់បន្ថយសិទ្ធិខាងសមាគម និងការជួបប្រជុំដោយសន្តិវិធីរបស់ពួក

គេឡើយ។ មាត្រា១៥ តម្រូវឱ្យរដ្ឋផ្តល់សិទ្ធិអំណាចដល់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ដើម្បីអនុវត្តសិទ្ធិចូលរួមរបស់ពួកគេ និងប្រឆាំងនឹងជម្រើសនានាដែលចេញដោយមណ្ឌលថែទាំ និងការរៀបចំដំបិនប្រសព្វដោយមនុស្សពេញវ័យ។

## *ទីកន្លែងសាធារណៈ*

៣៨. ក្រៅពីសមាគម និងការជួបប្រជុំដោយសន្តិវិធី នៅក្នុងបរិបទនៃសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គណៈកម្មាធិការសង្កត់ធ្ងន់លើសារៈសំខាន់នៃការគោរពជម្រើសរបស់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ចងជាសមាគមរួមគ្នានៅទីកន្លែងសាធារណៈ ដោយគ្មានការរំខានដល់សណ្តាប់ធ្នាប់សាធារណៈ ដើម្បីបំពេញបានសិទ្ធិរស់រានជីវិត និងអភិវឌ្ឍន៍របស់ខ្លួន(មាត្រា៦) ក្នុងការសម្រាក ការលេងកំសាន្ត និងការលំហែរ(មាត្រា៣១)[35] ដើម្បីចងក្រងជាបណ្តាញ និងរៀបចំជីវិតសង្គមរបស់ពួកគេ ហើយថាជាទិដ្ឋភាពសំខាន់មួយនៃជីវិតរបស់ពួកគេជាទូទៅ។ សម្រាប់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ការប្រមូលផ្តុំបែបនេះគឺជាផ្នែកមួយនៃជីវភាពរស់នៅ។ យើងមិនអាចយកសកម្មភាពបែបនេះ មកបែងចែកជាសកម្ម ភាពដាច់ដោយឡែកពីគ្នា ដូចជាការញ៉ាំ ការដេក ឬការកម្សាន្តនោះទេ។ ចំពោះកុមារដែលមិនស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ សកម្មភាពបែបនេះរបស់ពួកគេ ជាចំបងប្រព្រឹត្តទៅនៅទីតាំងដូចជាគ្រួសារ ផ្ទះ ឬសាលារៀន។ សម្រាប់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់វិញ សកម្មភាពបែបនេះប្រព្រឹត្តទៅនៅតាមទីកន្លែងសាធារណៈ។ កុមារ ក្រុមនេះចាំបាច់ត្រូវមានកន្លែងសុវត្ថិភាព ដែលពួកគេអាចអនុវត្តសិទ្ធិខាងសមាគមរបស់ពួកគេ ដែលត្រូវបានបកស្រាយនៅទីនេះ រួមជាមួយសិទ្ធិផ្សេងទៀតដែលត្រូវការពារ តាមអនុសញ្ញានេះថាជា "ការចំណាយពេលវេលាជាមួយអ្នកដទៃនៅកន្លែងសាធារណៈ"។ គណៈកម្មាធិការបានរកឃើញពីការថយចុះនៃការអត់ឱនដល់កុមារ នៅតាមទីកន្លែងសាធារណៈទាក់ទងនឹងមាត្រា៣១។[36] សេចក្តីពន្យល់ទូទៅនេះ មានបរិយាយពីការព្រួយបារម្ភទាំងនេះ ទាក់ទងនឹងការថយចុះនៃការអត់ឱនដល់ការប្រើប្រាស់ទីកន្លែងសាធារណៈរបស់កុមារក្នុងគោលបំណងផ្សេងក្រៅពីគោលបំណងដែលមានចែងក្នុងមាត្រា៣១។

---

[35] សូមមើលសេចក្តីពន្យល់ទូទៅលេខ១៧ (២០១៣) ស្តីពីសិទ្ធិកុមារក្នុងការសម្រាក ការលំហែរ លេងកម្សាន្ត ជីវិតវប្បធម៌ និងសិល្បៈ កថាខណ្ឌ២១។

[36] ដូចខាងលើ កថាខណ្ឌទី៣៧

## *ការដាក់កំហិតលើមាត្រា១៥*

៣៩. អនុលោមតាមមាត្រា១៥(២) ការរក្សាសណ្តាប់ធ្នាប់ឬវិធានការផ្សេងទៀតដែលទាក់ទងនឹងសណ្តាប់ ធ្នាប់សាធារណៈ អាចអនុញ្ញាតិបានលុះត្រាតែការចាត់វិធានការបែបនេះធ្វើឡើងដោយផ្អែកលើមូលដ្ឋានច្បាប់ វាយតម្លៃបុគ្គលម្នាក់ៗជាជាងការវាយតម្លៃជារួមអនុលោមតាមគោលការណ៍សមាមាត្រ និងជាតំណាងឱ្យជម្រើសនៃការបំពានតិចបំផុត។ វិធានការបែបនេះ មិនគួរត្រូវយកមកអនុវត្តលើក្រុម ឬសមូហភាពទេ។[37] នេះមានន័យថា ការឃាឃី អំពើហិង្សា ការចាប់ប្រមូល និងការប្រមូលពីផ្លូវនៃកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ រួមទាំងក្នុងបរិបទនៃព្រឹត្តិការណ៍ធំៗខាងនយោបាយ សាធារណៈឬកីឡា ឬកិច្ចអន្តរាគមន៍ដទៃទៀតដែលរឹតត្បិត ឬជ្រៀតជ្រែកដល់សិទ្ធិខាងសមាគម និងការជួបប្រជុំដោយសន្តិវិធីរបស់កុមារជាការប្រព្រឹត្តផ្ទុយនឹងមាត្រា១៥(២)។ ការមិនទទួលស្គាល់សហជីព និងអង្គការស្របច្បាប់ដែលដឹកនាំដោយកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ និង/ឬតម្រូវឱ្យមានអាជ្ញាប័ណ្ណសម្រាប់អង្គការទាំងនោះ ដែលកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់មិនមានសិទ្ធិទទួលបានការប្រើប្រាស់ដោយសមហេតុផល នឹងបង្កើតជាការរើសអើងប្រឆាំងនឹងពួកគេ និងមិនស្របតាមមាត្រា១៥(២)។

## *ការអនុវត្តវិធានការ*

៤០. រដ្ឋមិនគួររំខាន ឬចាប់បញ្ជូនដោយបំពាននូវកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ពីកន្លែងដែលពួកគេចងក្រងជាសមាគម និងជួបប្រជុំដោយសន្តិវិធី ក្នុងទីកន្លែងសាធារណៈឡើយ។ ត្រូវដាក់ទណ្ឌកម្មលើអ្នកដែលរំលោភបំពានសិទ្ធិនេះ។ ការបណ្តុះបណ្តាលឯកទេសត្រូវរៀបចំដើម្បីកសាងសមត្ថភាពរបស់នគរបាល និងកម្លាំងសន្តិសុខ ដែលដោះស្រាយស្ថានភាពសណ្តាប់ធ្នាប់សាធារណៈ តាមវិធីមួយដែលត្រូវលើកកំពស់ការគោរពសិទ្ធិកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។[38] លក្ខន្តិកៈរបស់រដ្ឋាភិបាលមូលដ្ឋាន គួរត្រូវបានពិនិត្យឡើងវិញ ដើម្បីធានាឲ្យស្របទៅនឹងមាត្រា១៥(២)។ រដ្ឋគួរតែគាំទ្រវិធានការជាវិជ្ជមានដូច

---

[37] សូមមើលសេចក្តីពន្យល់ទូទៅលេខ៦ (២០០៥) ស្តីពីការថែទាំកុមារដែលមិនមានអ្នកអមដំណើរ និងនៅដាច់ដោយឡែកពេលចេញក្រៅប្រទេសកំណើតរបស់ខ្លួន កថាខណ្ឌ១៨។ ត្រូវបានគាត់តែងជាដំបូង ចំពោះកុមារដែលមិនមានអ្នកអមដំណើរ និងនៅដាច់ដោយឡែក ដែលបានឆ្លងកាត់ព្រំដែនអន្តរជាតិ នៅក្នុងសេចក្តីពន្យល់ទូទៅនេះ គណៈកម្មាធិការពង្រីកការបកស្រាយនេះ សំដៅដល់កុមារទាំងអស់ស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។

[38] សូមមើលសេចក្តីពន្យល់ទូទៅលេខ១៣ កថាខណ្ឌទី៤៤

ជា៖ [១]ផ្តល់សិទ្ធិអំណាចដល់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ តាមរយៈការអប់រំសិទ្ធិកុមារ និងការអភិវឌ្ឍន៍បំណិនជីវិត [២]រៀបចំអ្នកពាក់ព័ន្ធនានាឱ្យទទួលយកទស្សនៈរបស់កុមារទាំងនេះ ក្នុងការធ្វើសេចក្តីសំរេច ដូចដែលបានសម្តែងចេញតាមរយៈសមាគម និងការជួបប្រជុំ និង[៣]លើកកម្ពស់ការចូលរួមរបស់កុមារទាំងនេះនៅក្នុងសកម្មភាពកំសាន្ត កីឡា សិល្បៈ និងវប្បធម៌ រួមជាមួយកុមារដទៃទៀតនៅក្នុងសហគមន៍។ ច្បាប់មិនគួរតម្រូវឱ្យសមាគមកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ឬការជួបប្រជុំដោយសន្តិវិធីរបស់ពួកគេ ត្រូវចុះបញ្ជីជាផ្លូវការដើម្បីទទួលបានការការពារក្រោមមាត្រា១៥ ឡើយ។

## *មាត្រា៧ ស្តីពីការចុះសំបុត្រកំណើត និងមាត្រា៨ ស្តីពីអត្តសញ្ញាណ*

៤១. កង្វះខាតភស្តុតាងនៃអត្តសញ្ញាណ មានផលប៉ះពាល់ជាអវិជ្ជមាន ទៅលើការការពារសិទ្ធិកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ លើផ្នែកអប់រំ សុខភាព និងសេវាសង្គមដទៃទៀត យុត្តិធម៌ ការស្នងមរតក និងការជួបជុំគ្រួសារឡើងវិញ។ យ៉ាងហោចណាស់ រដ្ឋគួរធានាថាការចុះសំបុត្រកំណើតត្រូវផ្តល់ឱ្យកុមារគ្រប់រូប គ្រប់វ័យ ដោយឥតគិតថ្លៃ អាចទៅធ្វើបានដោយងាយស្រួល សាមញ្ញ និងឆាប់រហ័ស។ កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់គួរទទួលបានការគាំទ្រកាន់តែសកម្ម ដើម្បីទទួលបានឯកសារសម្គាល់អត្តសញ្ញាណស្របច្បាប់។ ជាដំណោះស្រាយបណ្តោះអាសន្ន រដ្ឋ និងរដ្ឋបាលមូលដ្ឋាន គួរតែអនុញ្ញាតឱ្យមានដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត និងមានភាពបត់បែន ដូចជាការចេញអត្តសញ្ញាណប័ណ្ណក្រៅផ្លូវការ ដោយផ្អែកលើបុគ្គលិកអង្គការសង្គមស៊ីវិល/អាស័យដ្ឋានរបស់អង្គការនេះ ដោយអនុញ្ញាតិឱ្យកុមារ ក្នុងពេលទន្ទឹងគ្នានោះនូវការទទួលបានសេវា និងការការពារជាមូលដ្ឋាននៅក្នុងប្រព័ន្ធយុត្តិធម៌។ ដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតគួរតែត្រូវបានអនុម័ត ដើម្បីជំនះបញ្ហានានាដែលកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ប្រឈមដែលត្រូវផ្លាស់ទីជាញឹកញាប់ ហើយខ្វះមធ្យោបាយរក្សាឯកសារអត្តសញ្ញាណទាំងនេះឱ្យបានគត់មត់ ដោយមិនធ្វើឱ្យវាបាត់បង់ ឬខូចខាត ឬត្រូវគេលួច។

## មាត្រា១៣ ស្តីពីសេរីភាពនៃការបញ្ចេញមតិ និងមាត្រា១៧ ស្តីពីសិទ្ធិទទួលបានព័ត៌មាន

៤២. សិទ្ធិកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ក្នុងការទទួលបាន ស្វែងរក និងចែកផ្សាយព័ត៌មានអំពីសិទ្ធិរបស់ពួកគេ មានសារៈសំខាន់ណាស់ នៅពេលដែលសិទ្ធិទាំងនេះត្រូវបានយល់ដឹង និងសម្រេចបានក្នុងការអនុវត្តជាក់ស្តែង។ ក្នុងបរិបទជាក់លាក់ សិទ្ធិទទួលបានការអប់រំសម្រាប់កុមារ នឹងជួយជម្នះរបាំងនានាដែលជាឧបសគ្គដល់ការចូលរួមធ្វើដូច្នេះបាន សំលេងរបស់ពួកគេអាចត្រូវបានស្តាប់/ឮ។ តាមរយៈបណ្តាញព័ត៌មានដែលសមស្របនិងមានលក្ខណៈងាយស្រួល កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ត្រូវមានសិទ្ធិទទួលបានព័ត៌មានដែលត្រឹមត្រូវ គុណភាពខ្ពស់ និងមានលក្ខណៈកុមារមេត្រី ទាក់ទងនឹង៖ (ក) តួនាទី និងគណនេយ្យភាពរបស់រដ្ឋ និងយន្តការដោះស្រាយបណ្តឹងទាក់ទងនឹងការរំលោភសិទ្ធិមនុស្ស (ខ) ការការពារពីអំពើហិង្សា (គ) សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ រួមទាំងការធ្វើផែនការគ្រួសារនិងការបង្ការពីការឆ្លងជម្ងឺកាមរោគ (ឃ) របៀបរស់នៅប្រកបដោយសុខភាពល្អ រួមមានរបបអាហារ និងសកម្មភាពកីឡា (ង) ឥរិយាបថសង្គម និងផ្លូវភេទ ដែលមានសុវត្ថិភាព និងការគោរព (ច) ការបង្ការពីគ្រោះថ្នាក់ និង(ឆ) ផលប៉ះពាល់អវិជ្ជមាននៃការប្រើប្រាស់គ្រឿងស្រវឹង ថ្នាំជក់ គ្រឿងញៀននិងសារធាតុគ្រោះថ្នាក់ដទៃទៀត។

## មាត្រា១៦ ស្តីពីសិទ្ធិឯកជន កិត្តិយស និងកេរ្តិ៍ឈ្មោះ

៤៣. កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ អាចជួបនូវភាពឯកជនមានកម្រិត ដោយហេតុថាពួកគេត្រូវធ្វើសកម្មភាពនៅទីសាធារណៈ។ ការរើសអើង ដោយសារតែឪពុកម្តាយឬគ្រួសារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ធ្វើឱ្យពួកគេងាយរងគ្រោះជាពិសេស ចំពោះការរំលោភបំពានមាត្រា១៦។ គណៈកម្មាធិការទទួលស្គាល់ការបណ្តេញចេញដោយបង្ខំ ថាជាការរំលោភបំពានមាត្រា១៦នៃអនុសញ្ញានេះ ហើយគណៈកម្មាធិការសិទ្ធិមនុស្ស ធ្លាប់បានទទួលស្គាល់ថា វាជាការរំលោភបំពានមាត្រា១៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។[39] អនុសាសន៍ក្នុងកថាខណ្ឌទី២៧ លើកឡើងពីការធ្វើឱ្យទៅជាស្នាកស្នាមទុរយស និងក្នុងកថាខណ្ឌទី៦០ និយាយពីការប្រព្រឹត្តលើដោយមិនរើសអើង និងដោយការគោរព ពីមន្ត្រីនគរបាល ផ្តល់ការណែនាំទាក់ទងនឹងកិត្តិយស និងកេរ្តិ៍ឈ្មោះ។

[39] សូមមើល CCPR/CO/83/KEN កថាខណ្ឌទី២២ និងCCPR/C/BGR/CO/3 កថាខណ្ឌទី២៤

## គ. បរិស្ថានគ្រួសារ និងការថែទាំជំនួស

### *មាត្រា២០ ស្តីពីសិទ្ធិទទួលបានការការពារ និងជំនួយពិសេស សម្រាប់កុមារដែលត្រូវបានដកហូតពីបរិដ្ឋានគ្រួសារ*

### *ប្រភេទនៃការថែទាំ*

៤៤. សំរាប់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ដែលគ្មានអ្នកមើលថែបឋម ឬគ្មានអ្នកដែលទទួលបានសិទ្ធិមើលថែតាមមាត្រា២០ រដ្ឋជាអ្នកថែទាំជាក់ស្តែង ហើយមានកាតព្វកិច្ចធានាឱ្យមានការថែទាំជំនួស ដល់កុមារដែលត្រូវបានដកហូតពីគ្រួសារជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍។[40] ប្រភេទនៃការថែទាំរួមមាន (១)ការគាំទ្រផ្នែកសម្ភារៈ និងស្មារតីដល់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ តាមរយៈមនុស្សពេញវ័យ ដែលអាចជឿទុកចិត្តបាន បុគ្គលិកធ្វើការតាមចិញ្ចើមថ្នល់ឬការគាំទ្រពីមិត្តភក្តិ ដោយមិនតម្រូវឱ្យឬបង្ខំឱ្យកុមារប្រកាសបោះបង់ចំណងតាមចិញ្ចើមថ្នល់របស់ខ្លួន និង/ឬផ្លាស់ទៅកន្លែងស្នាក់នៅផ្សេងទៀតឡើយ (២)មណ្ឌលសំចត មណ្ឌលសង្គមកិច្ច ឬសហគមន៍ (៣)ជំរកពេលយប់ (៤)មណ្ឌលថែទាំពេលថ្ងៃ (៥)ការថែទាំឱ្យស្នាក់នៅបណ្តោះអាសន្នតាមផ្ទះជាក្រុម (៦)ការថែទាំដោយឪពុកម្តាយចិញ្ចឹម (៧)ការជួបជុំគ្រួសារឡើងវិញ និង(៨)ការរស់នៅឯករាជ្យ ឬជម្រើសថែទាំរយៈពេលវែង ដូចជាសុំកូនជាដើម។ ឧទាហរណ៍ ការដកហូតសេរីភាពនៅក្នុងមន្ទីរឃុំឃាំង ឬមណ្ឌលបិទជិត គឺមិនមែនជាទម្រង់នៃកិច្ចការការពារកុមារនោះទេ។

### *ការអនុវត្តអភិក្រមតាមសិទ្ធិកុមារ*

៤៥. កិច្ចអន្តរាគមន៍ដែលមិនគោរពកុមារថាជាភ្នាក់ងារសកម្មនៅក្នុងដំណើរការនៃការបញ្ជូនពួកគេចេញពីចិញ្ចើមថ្នល់ ទៅដាក់ក្នុងមណ្ឌលថែទាំជំនួស នឹងមិនទទួលបានជោគជ័យទេ៖ ជារឿយៗ កុមារនឹងត្រលប់មកចិញ្ចើមថ្នល់វិញនៅពេលពួកគេលួចរត់ចេញ ឬនៅពេលដែលកន្លែងស្នាក់នៅនោះមិនដំណើរការ។ ការដាក់កុមារនៅកន្លែងថែទាំបរាជ័យ នៅពេលដែលកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ត្រូវបានបញ្ជូនទៅរស់នៅកន្លែងមិនធ្លាប់ស្គាល់ និងនៅជាមួយសាច់ញាតិដែលពួកគេស្គាល់តិចតួច។ ដោយអនុវត្តអភិក្រមតាមសិទ្ធិកុមារចំពោះការបង្កើត និងការផ្តល់ជំរើសជំនួស រដ្ឋត្រូវធានាថាកុមារមិនត្រូវបានបង្ខំឱ្យពឹងផ្អែក

---

[40] សូមមើលសេចក្តីពន្យល់ទូទៅលេខ១៣ កថាខណ្ឌទី៣៣ និង៣៥

លើស្ថានភាពតាមចិញ្ចើមថ្នល់ដើម្បីរស់រានជីវិតនិង/ឬអភិវឌ្ឍន៍ខ្លួនទេ ហើយពួកគេក៏មិនត្រូវបានបង្ខំឱ្យទទួលយកកន្លែងរស់នៅថ្មីដែលផ្ទុយនឹងឆន្ទៈរបស់ខ្លួនដែរ។ តាមរយៈក្របខណ្ឌច្បាប់ បទប្បញ្ញត្តិ គោលនយោបាយ និងសេចក្តីណែនាំផ្សេងៗ រដ្ឋគប្បីធានាថា ទស្សនៈរបស់កុមារត្រូវបានពិគ្រោះ និងពិចារណាក្នុងការធ្វើសេចក្តីសម្រេចទាក់ទងនឹងទីកន្លែងរស់នៅ ការអភិវឌ្ឍន៍ និងការពិនិត្យឡើងវិញពីផែនការថែទាំ និងការទៅលេងគ្រួសារ។[41] រដ្ឋគប្បីគោរពតាមលក្ខខណ្ឌអន្តរជាតិដែលបានកំណត់ថា ការថែទាំក្នុងមណ្ឌល គឺជាជម្រើសចុងក្រោយ[42] ធានាថាកុមារមិនត្រូវបានដាក់ក្នុងការថែទាំជំនួសបើមិនចាំបាច់ និងធានាថាប្រសិនបើមានការថែទាំជំនួស ការថែទាំនេះ ត្រូវផ្តល់ឱ្យក្រោមលក្ខខណ្ឌសមស្របដោយឆ្លើយតបទៅនឹងសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ។[43] រដ្ឋគប្បីធានាថាមណ្ឌល និងកន្លែងស្នាក់នៅរបស់រដ្ឋនិងសង្គមស៊ីវិល មានសុវត្ថិភាព និងមានគុណភាពល្អ។ ចំពោះការដាក់ឱ្យរស់នៅជាមួយសមាជិកគ្រួសារ ដោយការពិគ្រោះយោបល់ជាមួយកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ត្រូវធ្វើដោយគិតដល់ឧត្តមប្រយោជន៍របស់ពួកគេ ត្រូវមានការរៀបចំនិងការតាមដានយ៉ាងប្រុងប្រយ័ត្នលើភាគីទាំងពីរ។ ចាំបាច់ត្រូវមានដំណាក់កាលអន្តរកាលនៃការផ្ទេរចេញពីចិញ្ចើមថ្នល់ទៅរស់នៅទីកន្លែងជាប់លាប់ណាមួយ ហើយប្រវែងនៃរយៈពេលនេះត្រូវសម្រេចទៅតាមករណីនីមួយៗរបស់កុមារ។ ការប្រើកម្លាំងនគរបាលឬមន្ទីរឃុំឃាំងដទៃទៀត ដើម្បីដាក់កុមារដោយសារតែខ្វះកន្លែងថែទាំជំនួស គឺមិនអាចទទួលយកបានទេ។

## *មាត្រា៩ ស្តីពីការបំបែកចេញពីឪពុកម្តាយ*

៤៦. កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ភាគច្រើនរស់នៅជាមួយក្រុមគ្រួសាររបស់ពួកគេ នៅតាមចិញ្ចើមថ្នល់ ឬនៅទីតាំងផ្សេងៗតាមផ្លូវ និង/ឬនៅតែបន្តរក្សាទំនាក់ទំនងជាមួយគ្រួសាររបស់ពួកគេ ដែលយើងចាំបាច់ត្រូវគាំទ្រការរក្សាទំនាក់ទំនងទាំងនោះ។ រដ្ឋមិនគួរបំបែកកុមារចេញពីក្រុមគ្រួសាររបស់ពួកគេ ដោយគ្រាន់តែគ្រួសារនោះរស់នៅតាមចិញ្ចើមថ្នល់ ឬធ្វើការរកស៊ីចិញ្ចឹមជីវិតតាមដងផ្លូវនោះទេ។ ដូចគ្នានេះដែរ រដ្ឋមិនគួរបំបែកទារក ឬកុមារ ដែលកើតចេញពីក្មេងដែលរស់តាមចិញ្ចើមថ្នល់ទេ។ ភាពក្រីក្រផ្នែកហិរញ្ញវត្ថុ និង

---

[41] សូមមើលសេចក្តីពន្យល់ទូទៅលេខ១២ កថាខណ្ឌទី៥៤ សេចក្តីពន្យល់ទូទៅលេខ៦ កថាខណ្ឌទី៤០ និងសេចក្តីពន្យល់ទូទៅលេខ៧ កថាខណ្ឌទី៣៦(ខ)

[42] សូមមើលសេចក្តីពន្យល់ទូទៅលេខ៣ កថាខណ្ឌទី៣៥។

[43] គោលការណ៍ណែនាំសម្រាប់ការថែទាំជំនួស សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ៦៤/១៤២ ឧបសម្ព័ន្ធ។

សម្ភារៈ ឬលក្ខខណ្ឌផ្ទាល់ និងមិនអាចប្រកែកបានពីភាពក្រីក្របែបនេះ មិនគួរជាយុត្តិកម្ម ចំពោះការបំបែកកុមារពីការថែទាំរបស់ឪពុកម្តាយឡើយ ប៉ុន្តែត្រូវមើលឃើញថាជាសញ្ញាមួយ ដែលទាមទារឱ្យមានការគាំទ្រសមស្របដល់គ្រួសារនោះ។[44] ដើម្បីបង្ការការបំបែកចេញរយៈពេលវែង រដ្ឋអាចគាំទ្រជម្រើសថែទាំបណ្តោះអាសន្ន ដែលគោរពដល់សិទ្ធិកុមារ សំរាប់កុមារដែលឪពុកម្តាយ ជាឧទាហរណ៍ ធ្វើចំណាកស្រុកក្នុងកំឡុងពេលជាក់លាក់ដើម្បីធ្វើការងារតាមរដូវក្នុងមួយឆ្នាំៗ។

## មាត្រា៣(៣)ស្តីពីបទដ្ឋានសម្រាប់មណ្ឌលថែទាំ និងការពារ សេវាកម្មនិងបរិក្ខារ និងមាត្រា២៥ស្តីពីការត្រួតពិនិត្យតាមកាលកំណត់ទៅលើកន្លែងទុកដាក់កុមារ

៤៧. ជាការចាំបាច់ ត្រូវបង្កើត ថែរក្សា និងតាមឃ្លាំមើលគុណភាពនៃសេវារបស់ស្ថាប័នរដ្ឋ និងមិនមែនរដ្ឋ ដើម្បីបង្ការកុំឱ្យកុមារធ្លាក់ក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ថាជាលទ្ធផលនៃភាពបរាជ័យពីការមិនបានបំពេញតាមសិទ្ធិទទួលបានថែទាំនិងការពាររបស់កុមារ និងសំរាប់ជាប្រយោជន៍ដល់កុមារដែលកំពុងស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់រួចទៅហើយ។ រដ្ឋគួរផ្តល់សេវាដែលមានការគោរពសិទ្ធិ មានគុណភាព និងគាំទ្រដល់អង្គការសង្គមស៊ីវិល ដើម្បីឱ្យធ្វើដូចគ្នា។ ស្ថាប័ន សេវាកម្ម និងបរិក្ខារដែលមិនមែនជារបស់រដ្ឋ សម្រាប់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ គប្បីទទួលបានការគាំទ្រ ធនធាន ការទទួលស្គាល់គុណភាព បញ្ញត្តិច្បាប់ និងការតាមឃ្លាំមើលដោយរដ្ឋ។ បុគ្គលិកដែលពាក់ព័ន្ធនឹងសេវាបែបនេះ គប្បីទទួលបានការបណ្តុះបណ្តាល ស្របតាមកថាខណ្ឌទី១៨។

## មាត្រា១៨ ស្តីពីការទទួលខុសត្រូវរបស់ឪពុកម្តាយ

៤៨. ការគាំទ្រដល់ឪពុកម្តាយ និងអាណាព្យាបាលស្របច្បាប់ មានសារៈសំខាន់ ដើម្បីបង្ការកុំឱ្យកុមារធ្លាក់ខ្លួនទៅក្នុងស្ថានភាពរស់នៅតាមចិញ្ចើមថ្នល់ និងពង្រឹងកម្មវិធីជួបជុំគ្រួសារឡើងវិញ សម្រាប់កុមារដែលកំពុងរស់នៅតាមចិញ្ចើមថ្នល់រួចទៅហើយ។ រដ្ឋមានកាតព្វកិច្ចផ្តល់ជំនួយសមស្របដល់ឪពុកម្តាយ និងអាណាព្យាបាលស្របច្បាប់ ក្នុងការបំពេញភារកិច្ចចិញ្ចឹមកូនរបស់ពួកគេ និងដើម្បីធានាដល់ការបង្កើតស្ថាប័ន បរិក្ខារទីតាំង និងសេវាកម្មថែទាំ

[44] សូមមើលសេចក្តីពន្យល់ទូទៅលេខ១៤ កថាខណ្ឌទី៦២។

កុមារ។ រដ្ឋគប្បីចាត់វិធានការលុបបំបាត់កម្លាំងជារចនាសម្ព័ន្ធ ដែលដាក់សម្ពាធទៅលើគ្រួសារ ឱ្យស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់។ បញ្ហាគន្លឹះដែលត្រូវដោះស្រាយរួមមាន៖ (១)កែលំអការអភិវឌ្ឍន៍សហគមន៍ដោយឈរលើមូលដ្ឋានសិទ្ធិក្នុងសហគមន៍ក្រីក្រ (២)បង្កើតបណ្តាញសុវត្ថិភាពសង្គមនិងសេដ្ឋកិច្ចដ៏គ្រប់ជ្រុងជ្រោយ (៣)ផ្តល់មណ្ឌលថែទាំពេលថ្ងៃដែលមានសុវត្ថិភាពនិងមានតំលៃសមរម្យ និងសេវាឯកទេសផ្សេងទៀត និង(៤)កែលំអសិទ្ធិទទួលបានលំនៅដ្ឋាន និងប្រាក់ចំណូលសមរម្យសម្រាប់គ្រួសារ។ បន្ថែមពីលើអភិក្រមជារចនាសម្ព័ន្ធ និងគោលនយោបាយ គ្រួសារងាយរងគ្រោះ ត្រូវការដំណោះស្រាយតាមករណីជាក់លាក់ ដែលមានការសម្របសម្រួលពីអ្នកវិជ្ជាជីវៈ ដែលបានទទួលការបណ្តុះបណ្តាលល្អ។ រដ្ឋគួរវិនិយោគ និងពង្រីកកម្មវិធីគាំទ្រគ្រួសារ ដោយឈរលើមូលដ្ឋានអភិក្រមតាមសិទ្ធិកុមារ ដែលត្រូវបានបង្ហាញឱ្យឃើញថា អាចបញ្ឈប់ការឆ្លងវាលដាលពីមួយជំនាន់ទៅមួយជំនាន់នូវលក្ខខណ្ឌដែលធ្វើឱ្យកុមារធ្លាក់ខ្លួនក្នុងស្ថានភាពតាមចិញ្ចើមថ្នល់កាន់តែធ្ងន់ធ្ងរឡើង។ រដ្ឋគប្បីចាត់វិធានការ ផ្តល់ការអប់រំជាសកលស្តីពីសិទ្ធិកុមារ និងពីភាពជាឪពុកម្តាយវិជ្ជមានសម្រាប់ឪពុក ម្តាយ និងអ្នកថែទាំទាំងអស់ ដោយផ្តល់អាទិភាព-តាមវិធីមិនធ្វើឱ្យធ្លាក់ក្នុងស្នាកស្នាមទុរយស- ចំពោះក្រុមគ្រួសារដែលមានកូនប្រឈមនឹងការធ្លាក់ទៅក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ ការអប់រំនេះគប្បីរួមមានសិទ្ធិកុមារដោយរួមទាំងរបៀបស្តាប់មតិយោបល់របស់កុមារ និងបញ្ចូលទស្សនៈរបស់ពួកគេទៅក្នុងការធ្វើសេចក្តីសម្រេច ការចិញ្ចឹមកូនបែបវិជ្ជមាន រួមទាំងជំនាញក្នុងការអនុវត្តវិន័យបែបវិជ្ជមាន ការដោះស្រាយជម្លោះបែបអហិង្សា និងការចិញ្ចឹមកូនឱ្យមានការផ្សាភ្ជាប់ទំនាក់ទំនងរវាងឪពុក-ម្តាយ និងកូន ព្រមទាំងការអភិវឌ្ឍន៍កុមារតូច។ សូមមើលកថាខណ្ឌទី៣៥ និងទី៤៩ ផងដែរ។

## ឃ. ជីវភាពរស់នៅសមរម្យ

### *មាត្រា២៧ ស្តីពីសិទ្ធិទទួលបានជីវភាពសមរម្យ*

### *ការគាំទ្រដល់ឪពុកម្តាយ អ្នកថែទាំ និងកុមារ*

៤៩. អនុលោមតាមមាត្រា២៧(៣) រដ្ឋគប្បីធានាថាកុមារទាំងអស់មានជីវភាពរស់នៅគ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍផ្លូវកាយ ផ្លូវចិត្ត ស្មារតី និងសីលធម៌ ដើម្បីបង្ការពួកគេកុំឱ្យធ្លាក់ខ្លួនទៅក្នុងស្ថានភាពរស់នៅតាមចិញ្ចើមថ្នល់ និងដើម្បីបំពេញសិទ្ធិកុមារដែលកំពុងរស់នៅតាមចិញ្ចើមថ្នល់រួចហើយ។ រដ្ឋត្រូវចាត់វិធានការសមស្រប ដើម្បីជួយដល់ឪពុកម្តាយ និងអ្នកដទៃដែលទទួលខុសត្រូវចំពោះកុមារ ក្នុងការអនុវត្តសិទ្ធិនេះ និងក្នុងករណីចាំបាច់ ត្រូវផ្តល់

ជំនួយសម្ភារៈ និងកម្មវិធីគាំទ្រ ជាពិសេសទាក់ទងនឹងអាហារូបត្ថម្ភ សម្លៀកបំពាក់ និងផ្ទះសម្បែង។ ការកំណត់ទាំងនេះ មិនបានដាក់កំហិតទៅលើឆន្ទានុសិទ្ធិរបស់រដ្ឋទេ។ ការអនុវត្តខាងលើនេះ ស្របតាមលក្ខខណ្ឌជាតិ និងតាមមធ្យោបាយរបស់រដ្ឋភាគី គប្បីត្រូវបានបកស្រាយរួមគ្នាជាមួយមាត្រា៤ ពោលគឺ ក្នុងវិសាលភាពជាអតិបរមានៃធនធានដែលរដ្ឋភាគីមាន និងក្នុងករណីចាំបាច់ នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាពិសេសទាក់ទងទៅនឹងករណីយកិច្ចរបស់រដ្ឋ ក្នុងការបំពេញកាតព្វកិច្ចស្នូលអប្បបរមាចំពោះសិទ្ធិសង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌។ ទាក់ទងនឹងជំនួយផ្នែកសម្ភារៈ កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ផ្តល់អាទិភាពដល់តម្រូវការជម្រកសុវត្ថិភាពសម្រាប់រស់នៅ អាហារ ព្រមទាំងការថែទាំវេជ្ជសាស្ត្រ និងការអប់រំដែលអាចងាយរកបាន និងដោយឥតគិតថ្លៃ តាមរយៈការគាំទ្ររបស់រដ្ឋដល់ឪពុកម្តាយនិងអ្នកថែទាំ ជាពិសេសទាក់ទងនឹងឧបត្ថម្ភធន លំនៅដ្ឋាន និងការរកប្រាក់ចំណូល។ ការបកស្រាយមាត្រា២៧(៣) មិនមែនកំណត់ត្រឹមតែវិធានការជួយដល់ឪពុកម្តាយ និងបុគ្គលដទៃដែលទទួលខុសត្រូវចំពោះកុមារប៉ុណ្ណោះទេ។ កាតព្វកិច្ចផ្តល់ជំនួយផ្នែកសម្ភារៈ និងកម្មវិធីគាំទ្រ ក្នុងករណីមានតម្រូវការ គប្បីត្រូវបានបកស្រាយថាផ្តោតលើការផ្តល់ជំនួយដោយផ្ទាល់ដល់កុមារផងដែរ។ ចំណុចនេះ មានភាពពាក់ព័ន្ធជាពិសេសចំពោះកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ដែលគ្មានទំនាក់ទំនងគ្រួសារ ឬមានគ្រួសារដែលមានសកម្មភាពបំពាន។ ជំនួយសម្ភារៈដោយផ្ទាល់ដល់កុមារក្នុងទម្រង់ជាសេវាកម្ម អាចត្រូវផ្តល់ជូនដោយរដ្ឋ ឬតាមរយៈអង្គការសង្គមស៊ីវិលដែលគាំទ្រដោយរដ្ឋ។ ចំពោះគ្រួសារដែលមានតែម្តាយឬឪពុក និងគ្រួសារដែលត្រូវបង្កើតថ្មីឡើងវិញ វិធានការរបស់រដ្ឋដើម្បីធានាដល់ការថែទាំកុមារ មានសារៈសំខាន់ជាពិសេស (សូមមើលមាត្រា២៧(៤))។

## *លំនៅដ្ឋានសមរម្យ*

៥០. សិទ្ធិទទួលបានលំនៅដ្ឋានគឺជាធាតុសំខាន់មួយនៃមាត្រា២៧ដែលពាក់ព័ន្ធជាពិសេសទៅនឹងកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ វាត្រូវបានបកស្រាយយ៉ាងទូលំទូលាយដោយគណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ថាជាសិទ្ធិរស់នៅកន្លែងណាមួយដែលមានសន្តិសុខ សន្តិភាព និងសេចក្តីថ្លៃថ្នូរ[45] ដែលបញ្ជាក់ថា គោលគំនិតនៃ "ភាពគ្រប់គ្រាន់/សមរម្យ" ទាក់ទងនឹងលំនៅដ្ឋានទាមទារឱ្យផ្តោតការយកចិត្តទុកដាក់ចំពោះ

---

45 សូមមើលសេចក្តីពន្យល់ទូទៅលេខ៤(១៩៩១)របស់គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ស្តីពីសិទ្ធិទទួលបានលំនៅដ្ឋានសមរម្យ កថាខណ្ឌ៧

(១)សិទ្ធិកាន់កាប់លំនៅដ្ឋានស្របច្បាប់ (២)ការមានសេវាកម្ម សម្ភារៈ បរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធ (៣)តម្លៃសមរម្យ (៤)អាចរស់នៅបាន (៥)ងាយស្រួលចេញចូល (៦)ទីតាំងល្អ និង (៧)មានលក្ខណៈបរិបូណ៌ខាងផ្នែកវប្បធម៌។[46] កុមារស្ថិតក្នុងចំណោមអ្នកដែលរងការឈឺចាប់ខ្លាំងជាងគេ ពីការបណ្តេញចេញដោយបង្ខំ។[47] ការបណ្តេញចេញដោយបង្ខំ រួមទាំងតាមរយៈការកំទេចលំនៅដ្ឋានមិនរៀបរយ ឬខុសច្បាប់ អាចធ្វើឱ្យជីវិតរបស់កុមារកាន់តែមានភាពមិនច្បាស់លាស់ ដោយបង្ខំពួកគេឱ្យដេកនៅតាមចិញ្ចើមថ្នល់ និងធ្វើឱ្យពួកគេប្រឈមទៅនឹងការបំពានសិទ្ធិបន្ថែមទៀត។ ប្រធានបទដ៏ទូលំទូលាយ មួយនៃការពិគ្រោះយោបល់ជាមួយកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់គឺភាពមិនសមរម្យ និងភាពមិនសមាមាត្រនៃ "ជំរក" មួយចំនួនដែលរដ្ឋចាត់ចែង និងអំពីកំរិតខ្ពស់នៃអំពើហិង្សា និងអសន្តិសុខនៅតាមជំរកនោះ ដោយសារតែបែបនេះ ដែលកុមារចង់ទៅរស់នៅតាមចិញ្ចើមថ្នល់ជាង។

*ការអនុវត្តវិធានការ*

៥១. រដ្ឋគប្បីចាត់វិធានការដោះស្រាយមូលហេតុនៃភាពក្រីក្រជារចនាសម្ព័ន្ធ និងវិសមភាពប្រាក់ចំណូលដើម្បីកាត់បន្ថយសម្ពាធ និងពង្រឹងគ្រួសារដែលមានស្ថានភាពមិនច្បាស់លាស់ ថាជាមធ្យោបាយមួយនៃការផ្តល់ការការពារបានល្អប្រសើរដល់កុមារ និងកាត់បន្ថយលទ្ធភាពរបស់កុមារដែលធ្លាក់ទៅក្នុងស្ថានភាពរស់នៅតាមចិញ្ចើមថ្នល់។ វិធានការបែបនេះ រួមមាន៖ (១)ដាក់ចេញនូវគោលនយោបាយប្រមូលពន្ធ និងចំណាយរបស់រដ្ឋ ដែលកាត់បន្ថយវិសមភាពសេដ្ឋកិច្ច (២)ពង្រីកការងារដែលមានប្រាក់ខែសមរម្យ និងឱកាសផ្សេងទៀតដើម្បីបង្កើតប្រាក់ចំណូល (៣)ដាក់ចេញនូវគោលនយោបាយគាំទ្រអ្នកក្រីក្រសម្រាប់ការអភិវឌ្ឍន៍តំបន់ជនបទនិងទីក្រុង (៤)បំបាត់អំពើពុករលួយ (៥)ដាក់ចេញនូវគោលនយោបាយ និងថវិកាដែលផ្តោតលើបញ្ហាកុមារ (៦)ពង្រឹងកម្មវិធីកាត់បន្ថយភាពក្រីក្រដែលផ្តោតលើកុមារនៅតំបន់ដែលមានចំណាកស្រុកខ្ពស់ និង(៧)ផ្តល់សន្តិសុខសង្គម និងកិច្ចគាំពារសង្គមឱ្យបានគ្រប់គ្រាន់។ ឧទាហរណ៍ជាក់លាក់ រួមមានកម្មវិធីផ្តល់ប្រយោជន៍ដល់កុមារ ដែលត្រូវបានប្រើនៅបណ្តាប្រទេសអឺរ៉ុប និងអាមេរិកខាងជើង និងកម្មវិធីផ្ទេរសាច់ប្រាក់ ដែលត្រូវបានណែនាំឱ្យប្រើនៅបណ្តាប្រទេសអាមេរិកឡាទីន និងបានអនុវត្តយ៉ាងទូលាយនៅក្នុងបណ្តាប្រទេស

[46] ដូចខាងលើ កថាខណ្ឌទី៨

[47] សូមមើលសេចក្តីពន្យល់ទូទៅលេខ៧(១៩៩៧) របស់គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ស្តីពីការបណ្តេញចេញដោយបង្ខំ កថាខណ្ឌទី១០

អាស៊ី និងអាហ្វ្រិក។ រដ្ឋគប្បីខិតខំប្រឹងប្រែង ដើម្បីឱ្យកម្មវិធីបែបនេះអាចបានដល់គ្រួសារងាយរងគ្រោះបំផុត ដែលមិនមានគណនីធនាគារ។ កិច្ចគាំទ្រផ្នែកសម្ភារៈ គប្បីផ្តល់ជូនដល់ឪពុកម្តាយ និងអ្នកថែទាំ និងកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ដោយផ្ទាល់ ហើយយន្តការ និងសេវាបែបនេះ គួរត្រូវបានរៀបចំ និងអនុវត្តក្រោមមូលដ្ឋាននៃអភិក្រមតាមសិទ្ធិកុមារ។ ពាក់ព័ន្ធនឹងលំនៅដ្ឋាន សុវត្ថិភាពនៃការកាន់កាប់ មានសារៈសំខាន់ណាស់សម្រាប់បង្ការកុមារពីការទៅរស់នៅក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ ចំណុចនេះរួមមាន ការទទួលបានលំនៅដ្ឋានសមរម្យ ប្រកបដោយសុវត្ថិភាព ដោយទទួលបានទឹកស្អាតប្រើប្រាស់ និងបរិក្ខារអនាម័យ។ កុមារ រួមទាំងអ្នកដែលរស់នៅក្នុងលំនៅដ្ឋានមិនរៀបរយ ឬខុសច្បាប់ មិនគួររងការបណ្តេញចេញដោយបង្ខំ មុនពេលមានការផ្តល់កន្លែងស្នាក់នៅជំនួសឱ្យបានសមរម្យនោះទេ៖ រដ្ឋតម្រូវឱ្យមានការផ្តល់ជូនសមស្រប សម្រាប់កុមារដែលរងផលប៉ះពាល់។ កុមារ និងការវាយតម្លៃពីផលប៉ះពាល់លើសិទ្ធិមនុស្ស គប្បីជាបច្ច័យមួយសម្រាប់ការងារអភិវឌ្ឍន៍ និងគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការជម្លៀសចេញឱ្យបានជាអតិបរមា។

## ខ. ពិការភាព និងសុខភាព

### មាត្រា២៣ ស្តីពីកុមារពិការ

៥២. កុមារពិការធ្លាក់ខ្លួនទៅក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ដោយសារហេតុផលផ្សេងៗគ្នា រួមទាំងកត្តាសេដ្ឋកិច្ចនិងសង្គម ហើយជួនកាលត្រូវបានកេងប្រវ័ញ្ចឱ្យសុំទាន។ រដ្ឋគប្បីចាត់វាល់វិធានការចាំបាច់ដើម្បី បង្ការ និងផ្តន្ទាទោសដោយចំពោះទៅលើការកេងប្រវ័ញ្ចបែបនេះ និងនាំជនល្មើសមកកាត់ទោស។[48] កុមារ ស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ អាចប្រឈមនឹងហានិភ័យនៃការក្លាយខ្លួនជាជនពិការដោយសារផលប៉ះពាល់អវិជ្ជមានពីទិដ្ឋភាពនៃជីវិតតាមចិញ្ចើមថ្នល់ ដូចជាអំពើហិង្សា ការកេងប្រវ័ញ្ច និងការប្រើប្រាស់គ្រឿងញៀន។ ពិការភាពផ្នែកសតិបញ្ញា និងផ្នែកចិត្តសង្គម អាចបណ្តាលឱ្យកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ងាយរងគ្រោះ ជាពិសេសពីការកេងប្រវ័ញ្ច និងអំពើរំលោភបំពាន។ រដ្ឋគប្បីអនុម័តវិធានការការពារពិសេស រួមទាំងការកំណត់ និងដកចេញនូវរបាំងឧបសគ្គដែលរារាំងកុមារពិការពីការទទួលបានសេវានានា រួមទាំងការអប់រំប្រកបដោយបរិយាប័ន្នផងដែរ។

---

[48] សូមមើលសេចក្តីពន្យល់ទូទៅលេខ៩ កថាខណ្ឌទី៧៦

## មាត្រា២៤ ស្តីពីសុខភាព[49] និងមាត្រា៣៣ ស្តីពីការប្រើប្រាស់គ្រឿងញៀន និងសារធាតុញៀន

៥៣. បរិយាកាសតាមចិញ្ចើមថ្នល់ អាចបង្កើនភាពងាយរងគ្រោះទាក់ទងនឹងបញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្ត។[50] បញ្ហាប្រឈមរួមមានអត្រាខ្ពស់នៃការប្រើប្រាស់គ្រឿងញៀន ការឆ្លងមេរោគអេដស៍[51] ជំងឺកាមរោគផ្សេងទៀត ការមានផ្ទៃពោះ អំពើហិង្សា (រួមទាំងអំពើហិង្សាពីមិត្តភក្តិ) គំនិតចង់ធ្វើអត្តឃាត និងការធ្វើអត្តឃាត ការប្រើប្រាស់ឱសថដោយខ្លួនឯងនូវថ្នាំដែលមិនមានបញ្ជីការត្រឹមត្រូវ និងការប៉ះពាល់ជំងឺឆ្លង ការបំពុលបរិស្ថាន និងគ្រោះថ្នាក់ចរាចរណ៍។ គណៈកម្មាធិការបានសង្កត់ធ្ងន់អំពីតម្រូវការអប់រំសុខភាព និងសេវាកម្មនានារួមទាំងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ស្របតាមតម្រូវការជាក់លាក់របស់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ ការអប់រំ និងសេវាកម្មបែបនេះ គួរតែមានលក្ខណៈកុមារមេត្រី ផ្តល់ការគាំទ្រគ្រប់ជ្រុងជ្រោយ អាចស្វែងរកបាន មិនគិតថ្លៃ រក្សាការសម្ងាត់ គ្មានការវិនិច្ឆ័យ គ្មានការរើសអើង គោរពការសម្រេចចិត្តជាស្វ័យភាពរបស់កុមារ ដោយមិនចាំបាច់មានការយល់ព្រមពីឪពុកម្តាយ។[52] សេវាសុខភាព គួរបង្កលក្ខណៈឱ្យគេអាចទទួលបានដោយមិនគិតពីទីតាំងរូបវ័ន្ត ឬឋានៈសង្គម។ កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ គួរទទួលបានសេវាថែទាំសុខភាពជាមូលដ្ឋានដោយឥតគិតថ្លៃ តាមរយៈសេវាគ្របដណ្តប់សុខភាពជាសកល និងគម្រោងគាំពារសង្គម។ រដ្ឋគប្បីបង្កើនសេវាបង្ការ ការព្យាបាល និងការស្តារនីតិសម្បទាសម្រាប់ការប្រើប្រាស់គ្រឿងញៀន រួមទាំងសេវាកាត់បន្ថយគ្រោះថ្នាក់ និងការព្យាបាល អាការៈបាក់ស្មារតី និងសេវាសុខភាពផ្លូវចិត្ត សម្រាប់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ សេវាកម្មទាំងនេះ គួរមានបុគ្គលិកជាអ្នកវិជ្ជាជីវៈដែលទទួលបានការបណ្តុះបណ្តាលអំពីសិទ្ធិកុមារ និងស្ថានភាពជាក់លាក់របស់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ រដ្ឋអាចលើកកម្ពស់កម្មវិធីមិត្តអប់រំមិត្ត ក្រោមការផ្តល់កិច្ចគាំទ្រសមស្របដែលអាចមានប្រសិទ្ធភាព ជាពិសេស ក្នុងការប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់គ្រឿងញៀន ការឆ្លងជម្ងឺកាមរោគ និងមេរោគអេដស៍។ ត្រូវផ្តោតការយកចិត្តទុកដាក់ពិសេសដើម្បីការពារកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ពីការពាក់ព័ន្ធក្នុងការជួញដូរគ្រឿងញៀន។

---

[49] សេចក្តីពន្យល់ទូទៅលេខ១៥ (២០១៣) ស្តីពីសិទ្ធិកុមារក្នុងការទទួលបានស្តង់ដារសុខភាពដែលអាចទទួលបានល្អបំផុត

[50] សូមមើលសេចក្តីពន្យល់ទូទៅលេខ៤ កថាខណ្ឌទី៣៤

[51] សូមមើលសេចក្តីពន្យល់ទូទៅលេខ៣ កថាខណ្ឌទី៣០

[52] ដូចខាងលើ កថាខណ្ឌទី២០-២១ សេចក្តីពន្យល់ទូទៅលេខ៤ កថាខណ្ឌទី១១ និង២៦ និងសេចក្តីពន្យល់ទូទៅលេខ១៥ ជាពិសេស កថាខណ្ឌទី៨ ១១និង២៨។

## ច. ការអប់រំ សកម្មភាពកម្សាន្ត និងវប្បធម៌

### មាត្រា២៨ ស្តីពីការអប់រំ

៥៤. ការទទួលបានការអប់រំដោយឥតគិតថ្លៃ មានសុវត្ថិភាព មានភាពពាក់ព័ន្ធ និងប្រកបដោយគុណភាព មានសារៈសំខាន់ខ្លាំងដល់ការការពារកុមារមិនឱ្យធ្លាក់ទៅក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ និងបំពេញបាននូវសិទ្ធិកុមារដែលកំពុងស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់រួចហើយ។ សម្រាប់កុមារភាគច្រើន វិស័យអប់រំតំណាងឱ្យចំណុចចំណងចុងក្រោយជាមួយសង្គមទាំងមូល។ រដ្ឋគប្បីផ្តល់ឱ្យបានគ្រប់គ្រាន់ ក្នុងនោះរួមមាន ការគាំទ្រដល់ឪពុកម្តាយ អ្នកថែទាំ និងក្រុមគ្រួសារ ដើម្បីធានាថាកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់អាចបន្តការរៀនសូត្រនៅសាលារៀន ហើយសិទ្ធិរបស់ពួកគេក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព ត្រូវបានការពារយ៉ាងពេញលេញ។ ជម្រើសនៃការអប់រំជាច្រើនមានភាពចាំបាច់ ដូចជា "ឱកាសចូលរៀនជាលើកទីពីរ" ថ្នាក់បំប៉ន សាលារៀនចល័ត ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលភ្ជាប់ទៅនឹងការស្រាវជ្រាវទីផ្សារ និងបន្តជាមួយនឹងការគាំទ្ររយៈពេលវែង លើសកម្មភាពបង្កើតប្រាក់ចំណូល និងច្រកដើម្បីទទួលបានការអប់រំក្នុងប្រព័ន្ធ តាមរយៈភាពជាដៃគូជាមួយសង្គមស៊ីវិល។ គ្រូបង្រៀនគប្បីទទួលបានការបណ្តុះបណ្តាលអំពីសិទ្ធិកុមារ និងកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ព្រមទាំងវិធីសាស្ត្របង្រៀនកុមារបែបចូលរួម ដោយដាក់កុមារជាមណ្ឌលកណ្តាល។

### មាត្រា២៩ ស្តីពីគោលបំណងនៃការអប់រំ[53]

៥៥. គោលបំណងនៃការអប់រំសម្រាប់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ គួរស្របតាមមាត្រា២៩ និងរួមបញ្ចូលផ្នែកអក្ខរកម្ម នព្វន្ត អក្ខរកម្មឌីជីថល បំណិនជីវិត ការអប់រំសិទ្ធិកុមារ ការអត់ឱនចំពោះភាពចម្រុះ និងការអប់រំពលរដ្ឋវិជ្ជា។ ការអប់រំបែបនេះមានសារៈសំខាន់ណាស់សម្រាប់ការបំពេញបាននូវសិទ្ធិកុមារដល់ការការពារ ការអភិវឌ្ឍន៍ និងការចូលរួម រួមទាំង ការពង្រឹងស្វ័យភាពរបស់ខ្លួន និងការផ្តល់ភាពអង់អាចដល់ពួកគេ ក្នុងការចរចាឱ្យបានកាន់តែប្រសើរអំពីស្ថានភាពគ្រោះថ្នាក់ ដើម្បីបង្ការកុមារពីការធ្លាក់ខ្លួនទៅក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ព្រមទាំងសម្រាប់កុមារដែលស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់រួចហើយ។ រដ្ឋគប្បីចាត់វិធានការដើម្បីផ្តល់ការអប់រំដែលមានគុណភាពល្អ ការអប់រំសិទ្ធិ

[53] សេចក្តីពន្យល់ទូទៅលេខ១ (២០០១) អំពីគោលបំណងនៃការអប់រំ។

កុមារ និងបំណិនជីវិតដោយឥតគិតថ្លៃ ឱ្យបានទូលំទូលាយដល់កុមារទាំងអស់ តាមរយៈកម្មវិធីសិក្សានៅសាលារៀន និងការអប់រំក្រៅប្រព័ន្ធ ក៏ដូចជាការអប់រំតាមចិញ្ចើមថ្នល់ ដើម្បីឈោងចាប់កុមារដែលបោះបង់ការសិក្សា។

## *មាត្រា៣១ ស្តីពីការសម្រាក ការលេងកំសាន្ត និងការលំហែរ*

៥៦. គណៈកម្មាធិការគូសបញ្ជាក់អំពីសិទ្ធិក្នុងការសម្រាក ការកំសាន្ត និងការលំហែរ ព្រមទាំងការចូលរួមនៅក្នុងសកម្មភាពសិល្បៈ និងវប្បធម៌។ កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ប្រើប្រាស់ការច្នៃប្រឌិតរបស់ខ្លួន ដើម្បីយកកន្លែងមិនផ្លូវការនៃចិញ្ចើមថ្នល់សម្រាប់ឱកាសលេងកំសាន្តរបស់ពួកគេ។[54] រដ្ឋគប្បីធានាថាពួកគេមិនត្រូវបានដាត់ចេញមិនឱ្យលេងតាមសួនច្បារ និងសួនកុមារ ក្នុងលក្ខណៈមួយដែលមានការរើសអើងឡើយ ឧទា. សំលៀកបំពាក់មិនស្អាតបាត[55] និងគប្បីអនុម័តនូវវិធានការជួយពួកគេអភិវឌ្ឍន៍ភាពច្នៃប្រឌិតរបស់ពួកគេ និងហ្វឹកហ្វឺនការលេងកីឡា រួមទាំងបរិក្ខារ និងឧបករណ៍កីឡា និងការលំហែចល័តផងដែរ។

## ង. អំពើហិង្សាលើកុមារ និងមិធានការការពារពិសេស

## *មាត្រា១៩ និង៣៩ ស្តីពីសេរីភាពរួចផុតពីគ្រប់ទម្រង់នៃអំពើហិង្សា[56]*

៥៧. អំពើហិង្សាគ្រប់ទម្រង់ ទាំងផ្លូវចិត្ត ផ្លូវកាយ ឬផ្លូវភេទ គឺជាបុព្វហេតុចម្បង និងជាផលវិបាករបស់កុមារដែលធ្លាក់ក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ អំពើហិង្សាគ្រប់ទម្រង់ មានការសាយភាយយ៉ាងទូលាយ លើជីវិតរបស់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ និងជាក្តីកង្វល់ចម្បងដែលលើកឡើងដោយកុមារខ្លួនឯងផ្ទាល់។ ត្រូវចាត់វិធានការជាក់លាក់ ចាំបាច់ និងបន្ទាន់ ដើម្បីការពារកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ រួមជាមួយអនុសាសន៍ទាំងអស់នៅក្នុងសេចក្តីពន្យល់ទូទៅលេខ១៣ វិធានការបែបនេះរួមមាន៖ (១)ការហាមឃាត់រាល់ទម្រង់នៃអំពើហិង្សា រួមទាំងការដាក់ទណ្ឌកម្មលើរាងកាយ (២)យន្តការដើម្បីឈោងចាប់

---

[54] សេចក្តីពន្យល់ទូទៅលេខ១៧

[55] ដូចខាងលើ កថាខណ្ឌ១៤៩

[56] សូមមើលសេចក្តីពន្យល់ទូទៅលេខ៣ កថាខណ្ឌ១៩ និង៣៦-៣៧ សេចក្តីពន្យល់ទូទៅលេខ៤ កថាខណ្ឌ២ និង២៣ សេចក្តីពន្យល់ទូទៅលេខ៨ (២០០៦) ស្តីពីសិទ្ធិកុមារក្នុងការការពារពីការធ្វើទណ្ឌកម្មលើរូបរាងកាយ និងទម្រង់នៃការដាក់ទណ្ឌកម្មឃោរឃៅ ឬបន្ទាបបន្ថោកផ្សេងទៀត និងសេចក្តីពន្យល់ទូទៅលេខ១៣។

កុមារងាយរងគ្រោះ នៅក្នុងដំណើរការនៃការផ្តាច់ទំនាក់ទំនងពីគ្រួសារ និងសហគមន៍ (៣)យន្តការរាយការណ៍ពីអំពើហិង្សា ការរើសអើង និងទម្រង់ដទៃទៀតនៃការរំលោភបំពានសិទ្ធិ និង(៤)យន្តការនាំយកជនល្មើសដែលបានប្រព្រឹត្តអំពើហិង្សាមកទទួលខុសត្រូវ មិនថាជាស្ថាប័នរដ្ឋ ឬមិនមែនរដ្ឋ ជាបុគ្គល ឬជាក្រុមឡើយ។ យន្តការពិសេសអាចត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយជាមួយបុគ្គល ដែលកុមារទាំងនេះបានរាយការណ៍ថាជាការគំរាមកំហែងដល់សុខុមាលភាពរបស់ពួកគេ ដូចជាសមាជិកមួយចំនួននៃមន្ត្រីនគរបាល និងជនដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលមានការចាត់តាំង និងការជួញដូរគ្រឿងញៀន។

## មាត្រា៣៤-៣៦ ស្តីពីការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចផ្លូវភេទ ការជួញដូរផ្លូវភេទ និងការកេងប្រវ័ញ្ចដទៃទៀត

៥៨. កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ងាយរងគ្រោះជាពិសេសទៅនឹងអំពើហិង្សាផ្លូវភេទ និងការកេងប្រវ័ញ្ច ហើយពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការលក់កុមារ ពេស្យាចារកុមារនិងរូបភាពអាសអាភាស កុមារ មានភាពពាក់ព័ន្ធជាពិសេសទៅនឹងពួកគេ។ ការឆ្លើយតបដែលឥតគិតចំពោះបញ្ហាយេនឌ័រ គប្បីធ្វើឡើងដោយអ្នកវិជ្ជាជីវៈ ដែលបានទទួលការបណ្តុះបណ្តាល ក្នុងការយល់ជ្រួតជ្រាបពីស្ថានភាពជាក់លាក់របស់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ កុមារអាចធ្លាក់ខ្លួនក្នុងស្ថានភាពនៅតាមចិញ្ចើមថ្នល់ តាមរយៈការជួញដូរ ដើម្បីកេងប្រវ័ញ្ចផ្លូវភេទ ឬកម្លាំងពលកម្ម និង/ឬអាចងាយរងគ្រោះទៅនឹងការជួញដូរសម្រាប់គោលបំណងបែបនេះ ព្រមទាំងការជួញដូរដើម្បីយកអវៈយវៈរាងកាយ និងទម្រង់ដទៃទៀតនៃការកេងប្រវ័ញ្ច នៅពេលដែលពួកគេនៅតាមចិញ្ចើមថ្នល់។

## មាត្រា៣២ ស្តីពីពលកម្មកុមារ

៥៩. គណៈកម្មាធិការជម្រុញឱ្យបណ្តារដ្ឋអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា៣២(២) នៃអនុសញ្ញានេះ និងអនុសញ្ញាស្តីពីអាយុអប្បបរមារបស់អង្គការពលកម្មអន្តរជាតិ ឆ្នាំ១៩៧៣ (លេខ១៣៨) និងអនុសញ្ញាស្តីពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ឆ្នាំ១៩៩៩ (លេខ១៨២) ដើម្បីការពារកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ពីការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច និងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។ សកម្មភាពប្រឆាំងពលកម្មកុមារ គប្បីរួមមានវិធានការគ្រប់ជ្រុងជ្រោយ រាប់បញ្ចូលការផ្តល់កិច្ចគាំទ្រដែលបង្កលក្ខណៈឱ្យកុមារអាចចូលទៅទទួលការអប់រំ និងការធានាឱ្យបាននូវកម្រិតជីវភាពគ្រប់គ្រាន់សម្រាប់កុមារ និងគ្រួសារ។ វិធានការ

បែបនេះគប្បីត្រូវបានបង្កើតឡើងដោយសហការជាមួយកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ និងអ្នកពាក់ព័ន្ធសំខាន់ៗដទៃទៀត ដើម្បីឆ្លុះបញ្ចាំងអំពីឧត្តមប្រយោជន៍របស់កុមារ និងធានាថាវិធានការទាំងនោះមិនបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានដោយចៃដន្យ ទៅលើការរស់រានជីវិត ឬការអភិវឌ្ឍន៍របស់កុមារ។ ការផ្តន្ទាទោសទៅលើការសុំទាន ឬការជួញដូរដែលគ្មានអាជ្ញាប័ណ្ណ អាចបណ្តាលឱ្យមានទម្រង់ធ្ងន់ធ្ងរបំផុតនៃការប្រព្រឹត្តដើម្បីរស់រានជីវិត ដូចជាអំពើធ្វើអាជីវកម្មផ្លូវភេទ។ គម្រោងសន្សំប្រាក់ដើម្បីអភិវឌ្ឍន៍ជំនាញគ្រប់គ្រងថវិកា និងការពារការរកប្រាក់ចំណូល សម្រាប់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ គឺជាគម្រោងដែលមានសារៈប្រយោជន៍។

## *មាត្រា៣៧ និងមាត្រា៤០ ស្តីពីយុត្តិធម៌អនីតិជន*

៦០. កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ទំនងត្រូវបានកំណត់គោលដៅរងការផ្តន្ទាទោស និងទីបំផុតធ្លាក់ខ្លួនទៅក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន ឬនីតិជន និងមិនសូវទំនងថានឹងទទួលបានអត្ថប្រយោជន៍ពីការបង្វែរ ជម្រើសដោយឡែកជំនួសឱ្យការឃុំឃាំង ឬការអនុវត្តន៍ស្តារនីតិសម្បទា ដោយសារតែពួកគេមិនអាចមានលទ្ធភាពទទួលបានការធានាឱ្យនៅក្រៅឃុំ និងអាចគ្មាននីតិជនដែលទទួលខុសត្រូវក្នុងការធានាពួកគេ។ ការប្រព្រឹត្តខុសរបស់មន្ត្រីនគរបាល ដូចជាការបៀតបៀន (រាប់ទាំងការលួចលុយ និងទ្រព្យសម្បត្តិរបស់កុមារ ការចាប់ប្រមូល ឬបញ្ជូនកុមារចេញតាមទំនើងចិត្ត ដែលជាញឹកញាប់សកម្មភាពទាំងនេះ ត្រូវបានធ្វើតាមបញ្ជាពីថ្នាក់លើ និង/ឬអ្នកនយោបាយ) អំពើពុករលួយ ការជំរិតទារប្រាក់ (ជំរិតយកប្រាក់ ឬការរួមភេទ) និងអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវភេទ គឺជាការរំលោភសិទ្ធិជាទូទៅ ដែលរដ្ឋគប្បី ផ្តន្ទាទោសជាបន្ទាន់។ គណៈកម្មាធិការមានការព្រួយបារម្ភអំពីការអនុវត្តន៍គោលនយោបាយ "មិនអធ្យា ស្រ័យដាច់ខាត" ដែលផ្តន្ទាទោសកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ និងនាំឱ្យមានការដាក់កុមារទៅក្នុងមណ្ឌលដោយបង្ខំ។ រដ្ឋគប្បីគាំទ្រដល់ការដាក់ពង្រាយកម្លាំងនគរបាលទៅតាមតំបន់គោលដៅ ដោយផ្តោតលើការការពារ ជាជាងការដាក់ទោសទណ្ឌទៅលើកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់និងអនុម័តឱ្យមានសេវានគរបាលពហុវប្បធម៌។ រដ្ឋគប្បីធានាឱ្យបាននូវសិទ្ធិទាំងអស់របស់កុមារគ្រប់រូប រួមទាំងកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ នៅក្នុងបរិបទនៃការស្តារនីតិសម្បទា ជាជាងការដាក់ទោសតាមប្រព័ន្ធយុត្តិធម៌អនីតិជន។[57]

[57] សូមមើលសេចក្តីពន្យល់ទូទៅលេខ៦ កថាខណ្ឌ៦១ និងសេចក្តីពន្យល់ទូទៅលេខ១០ កថាខណ្ឌ៦ ៨-៩ និង១៦។

### មាត្រា៣៨ ស្តីពីជំលោះប្រដាប់អាវុធ

៦១. ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ ក៏មានភាពពាក់ព័ន្ធដែរ ដោយសារកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ជាជនងាយរងគ្រោះពីការជ្រើសរើសឱ្យចូលបំរើកម្លាំងប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធ។ ជម្លោះអាចបណ្តាលឱ្យមានកុមារ ធ្លាក់ទៅក្នុងស្ថានភាពនៅតាមចិញ្ចើមថ្នល់ តាមរយៈការកាត់ផ្តាច់សង្វាក់នៃបណ្តាញសង្គម ការបំបែកពីគ្រួសារ ការជម្លៀសចេញពីសហគមន៍ ឬការបដិសេធយុទ្ធជនជាកុមារដែលកាត់រំសាយពីសហគមន៍។ ទាក់ទងនឹងការបង្ការ ការអប់រំអំពីសិទ្ធិកុមារ រួមទាំងការអប់រំអំពីសន្តិភាព និងគំនិតផ្តួចផ្តើមប្រឆាំងនឹងការជ្រើសរើសកុមារឱ្យចូលរួមក្នុងកម្លាំងប្រដាប់អាវុធត្រូវបញ្ជ្រាបឱ្យដល់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ អន្តរាគមន៍ដើម្បីកាត់បន្ថយផលប៉ះពាល់នៃជម្លោះប្រដាប់អាវុធឱ្យបានជាអប្បបរមា ត្រូវតែកាត់បន្ថយឱ្យកាន់តែសកម្មថែមទៀត ចំពោះការបំបែកកុមារពីគ្រួសារ និងគប្បីផ្តល់អាទិភាពចំពោះកម្មវិធីស្វែងរកគ្រួសារ។ កម្មវិធីដកហូតអាវុធ ការកាត់រំសាយកងទ័ព និងកម្មវិធីសមាហរណកម្មសម្រាប់កុមារ គប្បីគិតគូរដល់ថាមពលនៃចំណងទៅនឹងការរស់នៅតាមចិញ្ចើមថ្នល់ ថាជាបុព្វហេតុ និងផលវិបាកនៃការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ។

## VI. ការផ្សព្វផ្សាយ និងកិច្ចសហប្រតិបត្តិការ

### ការផ្សព្វផ្សាយ

៦២. គណៈកម្មាធិការផ្តល់អនុសាសន៍ថា រដ្ឋត្រូវផ្សព្វផ្សាយសេចក្តីពន្យល់ទូទៅនេះឱ្យបានទូលំទូលាយ នៅតាមស្ថាប័នរដ្ឋាភិបាល ច្បាប់ និងរដ្ឋបាល ដល់កុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ឪពុកម្តាយ និងអ្នកថែទាំ អង្គការវិជ្ជាជីវៈ សហគមន៍ វិស័យឯកជន និងសង្គមស៊ីវិល។ រាល់បណ្តាញផ្សព្វផ្សាយរួមមានប្រព័ន្ធផ្សព្វផ្សាយបោះពុម្ព អ៊ីនធឺណិត និងមធ្យោបាយទំនាក់ទំនងផ្ទាល់របស់កុមារ ដូចជាការនិទានរឿង និងមិត្តអប់រំមិត្តជាដើម គប្បីត្រូវបានយកមកប្រើប្រាស់។ សេចក្តីពន្យល់ទូទៅនេះ ចាំបាច់ត្រូវបកប្រែជាភាសាពាក់ព័ន្ធរួមទាំងភាសាសញ្ញា អក្សរស្ទាប ជាទម្រង់ងាយយល់សម្រាប់កុមារពិការ និងកុមារដែលចេះអក្សរតិចតួចផងដែរ។ វាក៏តម្រូវឱ្យមានជាសំណៅសមស្របតាមវប្បធម៌ និងតាមបែបកុមារមេត្រី និង សំណៅដែលមានរូបភាពច្រើនជាងអត្ថបទ ដោយរៀបចំសិក្ខាសាលា ដោយការអនុវត្តទៅតាមអាយុ និង ផ្តល់កិច្ចគាំពារជាក់លាក់ទៅតាមពិការភាព ដើម្បីពិភាក្សាអំពីអត្ថន័យរបស់វា ក៏ដូចជាវិធីសាស្រ្តអនុវត្តន៍ល្អបំផុត ព្រមទាំងដាក់បញ្ចូលវាទៅក្នុងការបណ្តុះ

បណ្តាលអ្នកវិជ្ជាជីវៈទាំងអស់ ដែលធ្វើការដើម្បី និងជាមួយកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់។ រដ្ឋក៏ត្រូវបានលើកទឹកចិត្តផងដែរ ឱ្យដាក់បញ្ចូលព័ត៌មានស្តីពីកុមារស្ថិតក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ ទៅក្នុងរបាយការណ៍របស់ខ្លួន ជូនគណៈកម្មាធិការ។

## កិច្ចសហប្រតិបត្តិការអន្តរជាតិ

៦៣. គណៈកម្មាធិការអំពាវនាវឱ្យរដ្ឋពង្រឹងការប្តេជ្ញាចិត្តជាអន្តរជាតិ កិច្ចសហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមក ក្នុងការបង្ការកុមារពីការធ្លាក់ខ្លួនទៅក្នុងស្ថានភាពតាមចិញ្ចើមថ្នល់ និងការពារកុមារដែលកំពុងស្ថិតនៅក្នុងស្ថានភាពតាមចិញ្ចើមថ្នល់រួចហើយ។ ការណ៍នេះ រួមមាន ការកំណត់ និងចែករំលែកការអនុវត្តផ្អែកលើសិទ្ធិជាមូលដ្ឋាន ដែលត្រូវបានបង្ហាញពីការស្រាវជ្រាវ គោលនយោបាយ ការតាមឃ្លាំមើលនិងការកសាងសមត្ថភាពដ៏មានប្រសិទ្ធភាព។ កិច្ចសហប្រតិបត្តិការទាមទារឱ្យមានការចូលរួមពីរដ្ឋ ទីភ្នាក់ងារ និងស្ថាប័នអង្គការសហប្រជាជាតិ និងអង្គការតំបន់ អង្គការសង្គមស៊ីវិល (រួមទាំងអង្គការ និងគ្រឹះស្ថានអប់រំដែលដឹកនាំដោយកុមារ) កុមារ វិស័យឯកជន និងក្រុមអ្នកប្រកបវិជ្ជាជីវៈ។ គណៈកម្មាធិការសូមលើកទឹកចិត្តដល់តួអង្គទាំងនេះឱ្យជំរុញបន្តនូវវប្បធម៌សន្ទនាថ្នាក់គោលនយោបាយកំរិតខ្ពស់ និងការស្រាវជ្រាវទាក់ទងនឹងគុណភាព ព្រមទាំងអន្តរាគមន៍ផ្អែកលើភស្តុតាងសម្រាប់ការបង្ការ និងការឆ្លើយតប។ ការណ៍នេះ រួមមានកិច្ចសន្ទនានៅថ្នាក់អន្តរជាតិ ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន។ កិច្ចសហប្រតិបត្តិការបែបនេះ អាចត្រូវយកមកដោះស្រាយចំពោះកិច្ចការពារកុមារឆ្លងដែនជាជនទេសន្តរប្រវេសន៍ ជនភៀសខ្លួន និងអ្នកស្វែងរកសិទ្ធិជ្រកកោន ព្រមទាំងជាជនរងគ្រោះ/អ្នករស់រានជីវិតពីការជួញដូរឆ្លងដែន។

&&&@&&&